PLAN INTERNATIONAL



# ២,៥ លាន ហេតុផល

## យុទ្ធសាស្ត្រប្រចាំប្រទេស (២០២១-២០២៦)

សហការក្នុងភាពជាដៃគូយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់សិទ្ធិអំណាចរបស់

**ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ២,៥លាននាក់**

នៅប្រទេសកម្ពុជា

# ២,៥ លាន ហេតុផល

សហការក្នុងភាពជាដៃគូយុទ្ធសាស្ត្រ
ដើម្បីលើកកម្ពស់សិទ្ធិអំណាចរបស់

**ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង**

## ២,៥លាននាក់

នៅប្រទេសកម្ពុជា ២០២១-២០២៦



# លើកកម្ពស់សិទ្ធិកុមារ
# និងសមភាពក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង
## នៅក្នុងភាពចម្រុះផ្សេងគ្នារបស់ពួកគេ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ៦
បុព្វកថា ៨
គោលបំណងរបស់យើង ១១
ជំនាញរបស់យើង ១៣
ចំណុចផ្លាស់ប្តូរសំខាន់ៗក្នុងយុទ្ធសាស្ត្រប្រចាំប្រទេសថ្មី ១៤
ទិដ្ឋភាពរួមនៃយុទ្ធសាស្ត្រប្រចាំប្រទេស ១៦
ការវិភាគស្ថានភាព ២៥
ក្របខ័ណ្ឌគោលនយោបាយ ២៦
ស្ថានភាពសិទ្ធិកុមារ និងសិទ្ធិក្មេងស្រី ២៧
ការអភិវឌ្ឍយុវជន ២៩
និន្នាការវិវត្តន៍ថ្មីៗ ២៩
មេរៀនទទួលបានពីយុទ្ធសាស្ត្រប្រចាំប្រទេសលើកមុន ៣១
ការឆ្លើយតបជាយុទ្ធសាស្ត្ររបស់អង្គការភ្លែនអន្តរជាតិកម្ពុជា ៣៤
សកម្មភាពរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា ៣៧
តើអង្គការភ្លែនអន្តរជាតិកម្ពុជានឹងអនុវត្តកម្មវិធីនៅកន្លែងណាខ្លះ ? ៤០
ការពិនិត្យតាមដាន និងវាយតម្លៃ ៤១
របៀបវារៈនៃការស្រាវជ្រាវ ៤១
ឧបសម្ព័ន្ធទី ១ ៖ កម្មវិធី និងយុទ្ធសាស្ត្រកិច្ចសហការស្វែងរកមតិគាំទ្រ ៤២
ឧបសម្ព័ន្ធទី ២ ៖ គោលបំណងរបស់ស្ថាប័ន ៥៨

**លើកស្ទួយសម្លេង និងគាំទ្រក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ក្នុងការទទួលបានចំណេះដឹង ជំនាញ និងទំនុកចិត្ត ដែលពួកគេត្រូវការ ដើម្បីបំពេញបានសិទ្ធិ និងសម្រេចបានសក្តានុពលពេញលេញរបស់ខ្លួន។**



# សេចក្តីថ្លែងអំណរគុណ

អង្គការភ្លែនអន្តរជាតិកម្ពុជា បានដឹកនាំដំណើរការអភិវឌ្ឍន៍យុទ្ធសាស្ត្រប្រចាំប្រទេសថ្មីតាមរយៈវិធីសាស្ត្រចូលរួមជាប្រព័ន្ធក្នុងរយៈពេលជាង ៨ខែ ដោយមានការដាក់បញ្ចូលទិន្នន័យដែលប្រមូលបានតាំងពីឆ្នាំ ២០១៨។[1] ដោយសារការរឹតត្បិតការធ្វើដំណើរអំឡុងពេលនៃវិបត្តិជំងឺកូវីដ១៩ អង្គការភ្លែនអន្តរជាតិកម្ពុជា ជាការិយាល័យប្រចាំប្រទេសដំបូងគេបង្អស់នៅអង្គការភ្លែនអន្តរជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលអភិវឌ្ឍយុទ្ធសាស្ត្រប្រចាំប្រទេសថ្មីធ្វើឡើងតាមប្រព័ន្ធអនឡាញ។ ចំណុចសំខាន់នៅក្នុងដំណើរការនេះគឺ ដើម្បីជម្រុញការចូលរួមកាន់តែប្រសើរឡើង និងមានភាពម្ចាស់ការ គឺការប្រជុំពិភាក្សាភាគច្រើនប្រើប្រាស់ភាសាខ្មែរច្រើនជាងភាសាអង់គ្លេស។
ការអភិវឌ្ឍយុទ្ធសាស្ត្រប្រចាំប្រទេសសម្រាប់រយៈពេល ៥ឆ្នាំខាងមុខ ត្រូវបានដឹកនាំដោយក្រុមការងារស្នូល រួមមាន បុគ្គលិកជាន់ខ្ពស់ ៨នាក់ និងបុគ្គលិកតំណាងមកពីតំបន់ប្រតិបត្តិកម្មវិធី ២នាក់។ សម្រាប់ក្រុមធំមានចំនួនបុគ្គលិក ៣៧នាក់ រួមមាន បុគ្គលិកវ័យក្មេង និងបុគ្គលិកជាជនជាតិដើមភាគតិច ប្រហែល ១/៤ នៃចំនួនអ្នកចូលរួមសរុប។ អង្គការភ្លែនអន្តរជាតិកម្ពុជាបានអនុវត្តផែនការជំរុញការចូលរួមរបស់បុគ្គលិក ដោយរួមបញ្ចូលបុគ្គលិកទាំងអស់តាមរយៈយុទ្ធសាស្ត្រទំនាក់ទំនងដែលផ្តល់ឱកាសឱ្យបុគ្គលិកអាចសួរលើកឡើងនូវការព្រួយបារម្ភ និងយោបល់ផ្សេងៗ ដើម្បីកែលម្អការអនុវត្តកាន់តែប្រសើរឡើង។

**អង្គការភ្លែនអន្តរជាតិកម្ពុជា សូមថ្លែងអំណរគុណចំពោះ អ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម នៅក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រប្រចាំប្រទេសថ្មីនេះ។**



ដំណើរការអភិវឌ្ឍន៍យុទ្ធសាស្ត្រប្រចាំប្រទេសបានបញ្ចប់ជាផ្លូវការនៅខែឧសភា ឆ្នាំ២០២១ ដោយមានកិច្ចប្រជុំជាច្រើនតាមរយៈប្រព័ន្ធអនឡាញត្រូវបានរៀបចំឡើងទៅតាមដំណាក់កាលនីមួយៗ និងមានការចូលរួមពីគណៈគ្រប់គ្រង និងបុគ្គលិកអង្គការភ្លែនអន្តរជាតិកម្ពុជា ក្រសួងពាក់ព័ន្ធ (ជាពិសេស ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល) ស្ថាប័នអង្គការសហប្រជាជាតិ (ជាពិសេស បុគ្គលិក UNFPA និងបុគ្គលិក UNICEF មកពីផ្នែកផ្សេងៗ) និងក្លឹបកុមារ/ក្លឹបយុវជន។ **ការពិគ្រោះយោបល់ទាំងនេះគូសបញ្ជាក់ពីចំណុចសំខាន់ៗ ចំនួន ៣។ ចំណុចសំខាន់ទី១** អង្គការភ្លែនអន្តរជាតិកម្ពុជា កន្លងមកមានកេរ្តិ៍ឈ្មោះល្អចំពោះស្នាដៃការងារដែលសម្រេចបានជាមួយក្រសួងពាក់ព័ន្ធសំខាន់ៗ ហើយត្រូវបានទទួលស្គាល់ជាដៃគូអភិវឌ្ឍន៍ដែលគួរឱ្យជឿជាក់ និងជាអ្នកអនុវត្តន៍មានសមត្ថភាព ទាំងនៅកម្រិតអភិវឌ្ឍគោលនយោបាយ និងកម្រិតអនុវត្តន៍។ **ចំណុចសំខាន់ទី២** អង្គការភ្លែនអន្តរជាតិកម្ពុជា បានផ្លាស់ប្តូរកម្មវិធីស្នូលរបស់ខ្លួនទៅជាកម្មវិធីពហុវិស័យ ដែលការផ្លាស់ប្តូរនេះត្រូវបានផ្តល់តម្លៃខ្ពស់ដោយរាជរដ្ឋាភិបាល ក៏ដូចជាដៃគូពហុភាគី រួមមាន UNFPA និង UNICEF និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិជាច្រើនទៀត។ **ចំណុចសំខាន់ទី៣** អង្គការភ្លែនអន្តរជាតិកម្ពុជា មានបេសកកម្មថ្មីផ្តោតសំខាន់ទៅលើក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ដែលគោលដៅក្នុងយុទ្ធសាស្ត្រថ្មីនេះគឺជាចំណុចលេចធ្លោរ និងឈានទៅរកការដោះស្រាយបញ្ហាដែលក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង កំពុងជួបប្រទះ ដោយពួកគេទាំងនោះកំពុងរង់ចាំអន្តរាគមន៍របស់យើងដោយក្តីរីករាយ!

---

[1] រួមមាន ការរៀបចំប្រតិបត្តិការឡើងវិញ (ខែសីហា ឆ្នាំ២០១៨), ការអភិវឌ្ឍយុទ្ធសាស្ត្រកិច្ចសហការស្វែងរកមតិគាំទ្រ (ខែមិថុនា ឆ្នាំ ២០១៩), ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រប្រចាំប្រទេស (ខែធ្នូ ឆ្នាំ២០១៩) ការស្ទង់មតិដើម្បីទទួលបានមតិត្រលប់ជាមួយអង្គការដៃគូ (ខែឧសភា ឆ្នាំ២០២០), ការវិភាគគោលនយោបាយជាតិស្តីពីសមធម៌យេនឌ័រ (ខែមិថុនា ឆ្នាំ២០២០) សកម្មភាព GEISA ជាបន្តបន្ទាប់។

# ដំណើរការអភិវឌ្ឍន៍យុទ្ធសាស្ត្រប្រចាំប្រទេស តាមរយៈការជួបប្រជុំដោយផ្ទាល់ និងពីចម្ងាយតាមប្រព័ន្ធអនឡាញ



# បុព្វកថា



**គ្រីននេត វ៉ែង**

**នាយិកាប្រចាំប្រទេស**

អង្គការភ្លែនអន្តរជាតិកម្ពុជា

យើងខ្ញុំសូមស្វាគមន៍ និងថ្លែងអំណរគុណចំពោះចំណាប់អារម្មណ៍របស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ទៅលើយុទ្ធសាស្ត្រប្រចាំប្រទេសទី ៤ របស់អង្គការភ្លែនអន្តរជាតិកម្ពុជា ដែលយុទ្ធសាស្ត្រនេះគឺជាត្រីវិស័យដឹកនាំបេសកកម្ម របស់យើងចាប់ពីខែកក្កដា ឆ្នាំ២០២១ រហូតដល់ ខែមិថុនា ឆ្នាំ២០២៦។ អង្គការភ្លែនអន្តរជាតិខិតខំប្រឹងប្រែងដើម្បីពិភពលោកយុត្តិធម៌មួយ ដែលលើកកម្ពស់សិទ្ធិកុមារ និងសមភាពក្មេងស្រី។ នៅប្រទេសកម្ពុជា អង្គការភ្លែនអន្តរជាតិ មានបេសកកម្មប្រកបដោយមហិច្ឆតាសម្រាប់រយៈពេល ៥ឆ្នាំខាងមុខ តាមរយៈកិច្ចសហការក្នុងភាពជាដៃគូយុទ្ធសាស្ត្រដើម្បីលើកកម្ពស់សិទ្ធិអំណាចរបស់ ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅកម្ពុជា និងលើកស្ទួយសម្លេងនៃពិពិធភាព (ភាពចម្រុះផ្សេងគ្នា) របស់ពួកគេ ហើយគាំទ្រពួកគេក្នុងការទទួលបាន ចំណេះដឹង ជំនាញ និងទំនុកចិត្ត ដែលពួកគេត្រូវការដើម្បីបំពេញបានសិទ្ធិ និងសម្រេចបានសក្តានុពលពេញលេញរបស់ខ្លួន។ នៅឆ្នាំ ២០២៦ យើងមានគោលដៅផ្តោតលើ ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅប្រទេសកម្ពុជាចំនួន ២,៥លាននាក់ (អ្នកទទួលផលផ្ទាល់ចំនួន ១លាននាក់ និងអ្នកទទួលផលដោយប្រយោលចំនួនប្រមាណ ១,៥លាននាក់)។ អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងខិតខំប្រឹងប្រែងដើម្បីសម្រេចគោលដៅទាំងនេះ តាមរយៈការអនុវត្តកម្មវិធីពហុវិស័យចំនួន ៤ ដោយប្រើប្រាស់អភិក្រមវដ្តជីវិត៖ **១.ការចាប់ផ្តើមជាមួយសុខភាពល្អ ២.កិច្ចការពារជំនាន់ថ្មី ៣.រៀនមួយជីវិត និង ៤.ភាពដឹកនាំរបស់ក្មេងស្រី។**

ដើម្បីសម្រេចបានគោលដៅរបស់ខ្លួននៅក្នុងការគាំទ្រការបំពេញបានសិទ្ធិកុមារ និងសិទ្ធិក្មេងស្រី និងសមភាពយេនឌ័រសម្រាប់ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងបន្តពង្រីកកិច្ចសហការជាមួយស្ថាប័នសង្គមស៊ីវិល (ឧ. បណ្តាញយុវជន) ពង្រឹងសមត្ថភាពរបស់អង្គការដៃគូ បង្កើតកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលមានទស្សនវិស័យដូចគ្នា[2] និង បន្តកិច្ចខិតខំប្រឹងប្រែងស្វែងរកមតិគាំទ្រប្រកបដោយប្រសិទ្ធភាពដែលពាក់ព័ន្ធនឹងបទបញ្ញត្តិ (ទាំងការបង្កើតគោលនយោបាយ និងការអនុវត្តគោលនយោបាយ)។ សម្រាប់យុទ្ធសាស្ត្រប្រចាំប្រទេសលើកមុន អង្គការភ្លែនអន្តរជាតិកម្ពុជា ត្រូវបានគេទទួលស្គាល់ស្នាដៃយ៉ាងច្រើនជាសាធារណៈ ចំពោះសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រប្រកបដោយប្រសិទ្ធភាពទៅលើបទបញ្ញត្តិសំខាន់ៗជាច្រើន។

[2] ជាពិសេស កិច្ចសហការរួមគ្នារវាងសម្ព័ន្ធមូលនិធិកុមារ អង្គការភ្លែនអន្តរជាតិ អង្គការសង្គ្រោះកុមារអន្តរជាតិ អង្គការភូមិកុមារ អេស អូ អេស កម្ពុជា និងសហព័ន្ធ Terre des Hommes អន្តរជាតិ និងអង្គការទស្សនៈពិភពលោកអន្តរជាតិ ដែលមានបណ្តាញការងារពីរពាក់ព័ន្ធនឹងសិទ្ធិកុមារ និងការបញ្ឈប់អំពើហិង្សាលើកុមារ។

អង្គការក្លែនអន្តរជាតិកម្ពុជា បានគាំទ្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្នុងការបង្កើតគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ (NPCPS) ឆ្នាំ ២០១៩-២០២៩ និងផែនការអនុវត្តគោលនយោបាយនេះ។ ក្រៅពីនេះអង្គការក្លែន អន្តរជាតិកម្ពុជាបានសហការជាមួយអង្គការ UNICEF គាំទ្រក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាក់តែងច្បាប់ស្តីពីកិច្ចការពារកុមារ។ អង្គការក្លែនអន្តរជាតិកម្ពុជា ជាដៃគូដ៏សំខាន់មួយដែលបានជួយជ្រោមជ្រែងនាយកដ្ឋានអប់រំកុមារតូចនៃ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផលិតឯកសារបណ្តុះបណ្តាល និងអប់រំ ដោយរួមបញ្ចូលទស្សនទានយេនឌ័រ និងផ្តល់ការបណ្តុះបណ្តាលផ្ទាល់ដល់មន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការអភិវឌ្ឍការប្រែក្លាយជាគម្រោងដែលមានទស្សនទានយេនឌ័រ។ល។

សម្រាប់យុទ្ធសាស្ត្រប្រចាំប្រទេសថ្មីនេះ អង្គការក្លែនអន្តរជាតិកម្ពុជា នៅតែមានគោលជំហររឹងមាំក្នុងការបន្តកិច្ចសហការស្វែងរកមតិគាំទ្ររបស់ខ្លួន តាមរយៈការបន្តចូលជាសមាជិកនៃគណៈកម្មការការពារកុមារថ្នាក់ជាតិ គណៈកម្មាធិការជាតិដឹកនាំការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់/ឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ក្រុមការងារបច្ចេកទេសជាច្រើនផ្សេងទៀត។

ការចុះអនុស្សារណៈយោគយល់គ្នាថ្មីមួយជាមួយក្រសួងកិច្ចការនារី នឹងផ្តល់ឱកាសឱ្យអង្គការក្លែនអន្តរជាតិកម្ពុជា អាចគាំទ្រដល់បទបញ្ញត្តិ និងការអនុវត្តដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

## ខាងក្រោមនេះជាចំណុចផ្លាស់ប្តូរសំខាន់ៗ ក្នុងយុទ្ធសាស្ត្រថ្មី៖

១. **ការផ្តោតសំខាន់លើក្រុមគោលដៅ និងទីតាំងមួយចំនួនដែលជួបការលំបាកបំផុតក្នុងប្រទេសកម្ពុជា។** ទោះបីជាប្រទេសកម្ពុជាមានអន្តរាគមន៍ជាច្រើនពីរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិក៏ដោយ ក៏ប្រជាពលរដ្ឋខ្មែរមួយចំនួននៅតែជួបការលំបាក និងមិនទទួលបានឱកាស ជាពិសេស ក្រុមក្មេងស្រី ក្រុមជនជាតិដើមភាគតិច ក្រុមមានពិការភាព និងក្រុមមានទំនោរនិន្នាការស្រឡាញ់ភេទដូចគ្នា។ ដូច្នេះហើយទើបក្រុមទាំងអស់នេះក្លាយជាក្រុមគោលដៅសំខាន់នៅក្នុងការអនុវត្តយុទ្ធសាស្ត្រប្រចាំប្រទេសថ្មីរបស់អង្គការក្លែនអន្តរជាតិកម្ពុជា។

២. **កម្មវិធីពហុវិស័យនៅក្នុងអភិក្រមវដ្តជីវិត។** គម្រោងមិនត្រូវបានអនុវត្តដោយផ្តោតលើវិស័យជាក់លាក់ណាមួយទេ ប៉ុន្តែអង្គការក្លែនអន្តរជាតិកម្ពុជា បានបង្កើតកម្មវិធីស្នូលពហុវិស័យចំនួន ៤ ដោយកម្មវិធីស្នូលនីមួយៗ រួមបញ្ចូលនូវវិស័យជាច្រើន គឺដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវ គោលបំណង និងសេវាជារួម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

៣. **គោលការណ៍ភាពជាអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រ។** តាមរយៈយុទ្ធសាស្ត្រថ្មីនេះ អង្គការក្លែនអន្តរជាតិកម្ពុជា នឹងខិតខំបន្ថែមទៀតដើម្បីជម្រុញបេសកកម្មរបស់ខ្លួនអាចសម្រេចជោគជ័យដោយអនុលោមតាមគោលការណ៍ និងគុណតម្លៃជារួមរបស់ស្ថាប័នទាំងមូល។ អង្គការក្លែនអន្តរជាតិកម្ពុជាប្តេជ្ញាកសាងវប្បធម៌នៃភាពជាអ្នកដឹកនាំដែលលើកកម្ពស់ការចូលរួម និងទំនួលខុសត្រូវរបស់ស្ត្រី ទៅលើការអនុវត្តការងារដែលឈានទៅសម្រេចបានជម្រើសជាយុទ្ធសាស្ត្ររបស់ខ្លួន។ យើងនឹងបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតវប្បធម៌វិជ្ជមានដែលចែករំលែកអំណាច លុបបំបាត់ភាពលម្អៀង ជំរុញបរិយាបន្ន និងលើកទឹកចិត្តឱ្យមានស្វ័យថែទាំ និងការយកចិត្តទុកដាក់ចំពោះអ្នកដទៃ។

៤. **ការផ្លាស់ប្តូរតំបន់ភូមិសាស្ត្រគោលដៅ។** ដោយសារអង្គការក្លែនអន្តរជាតិកម្ពុជាផ្តោតសំខាន់លើក្រុមគោលដៅដែលជួបការលំបាក និងមិនទទួលបានឱកាស ដូច្នេះហើយ ទើបអង្គការនៅតែកំណត់ខេត្តភាគឦសានចំនួន ២ (ខេត្តរតនគិរី និងស្ទឹងត្រែង) នៃប្រទេសកម្ពុជា ជាតំបន់គោលដៅអាទិភាពដដែល  ហើយប្រហែលជាអាចនឹងពង្រីកតំបន់ប្រតិបត្តិការទៅខេត្តឧត្តរមានជ័យមួយបន្ថែមទៀត។ បេសកកម្មក្នុងខេត្តសៀមរាបនៅតែបន្តដដែល ប៉ុន្តែសកម្មភាពមួយចំនួនអាចនឹងត្រូវបានបិទបញ្ចប់បន្តិចម្តងៗ ដោយសារតែមានស្ថាប័នចម្រុះជាច្រើនអនុវត្តសកម្មភាពនៅក្នុងខេត្តនេះ ហើយអង្គការក្លែនអន្តរជាតិកម្ពុជាក៏ឈរជើងនៅទីនោះអស់រយៈពេលជិត ២០ឆ្នាំ ដែរ។

ខណៈពេលដែលយើងប្រកាសអនុវត្តយុទ្ធសាស្ត្រប្រចាំប្រទេសថ្មីនេះ ស្ថានភាពនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាពិភពលោកទាំងមូល កំពុងតែទទួលរងផលប៉ះពាល់ដោយសារជំងឺរាតត្បាតកូវីដ១៩។ វិបត្តិនេះនឹងបន្តជះឥទ្ធិពលអវិជ្ជមានលើជីវិតរស់នៅ និងឱកាសរបស់ប្រជាពលរដ្ឋក្រីក្រ និងជួបការលំបាកបំផុតនៅប្រទេសកម្ពុជាក្នុងរយៈពេល ២-៣ឆ្នាំ តទៅមុខទៀត [3]។ អ្នករកប្រាក់កម្រៃចិញ្ចឹមជីវិតប្រចាំថ្ងៃរាប់ពាន់នាក់ បានបាត់បង់ប្រភពចំណូលចម្បងរបស់ខ្លួន ដែលជាមធ្យម ចំណូលរបស់ពួកគេថយចុះជិតពាក់កណ្តាល (មកត្រឹម ៣៥ដុល្លារ/សប្តាហ៍)។ ដូច្នេះ គ្រួសារត្រូវបង្ខំចិត្តប្រើយន្តការដោះស្រាយដែលមានគ្រោះថ្នាក់ដើម្បីការរស់រាន៖ គ្រួសារ ៣៨% កាត់បន្ថយចំណាយលើម្ហូបអាហារ គ្រួសារ ៣៧% ជំពាក់បំណុលកាន់តែច្រើន និងគ្រួសារ ៣៦% ដកប្រាក់សន្សំមកចាយវាយ។ ច្បាស់ណាស់ថា ជំងឺកូវីដ ១៩ កំពុងបង្កផលប៉ះពាល់អវិជ្ជមានលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ការអប់រំ និងការរៀនសូត្រក៏ទទួលរងផលប៉ះពាល់អវិជ្ជមានផងដែរ ជាពិសេស សម្រាប់ប្រជាជនជួបការលំបាក និងក្រីក្រ។ កុមារ ១/៣ លើកឡើងថា អំឡុងពេលដែលសាលាបិទ ពួកគេមិនបានរៀនសូត្រនោះទេ (ដោយសារកង្វះការគាំទ្រពីឪពុកម្តាយ កង្វះវិន័យផ្ទាល់ខ្លួន និងសមត្ថភាពចូលរួមក្នុងការសិក្សាតាមប្រព័ន្ធអនឡាញ កង្វះលទ្ធភាពប្រើប្រាស់សេវាអ៊ីនធឺណិត គ្មានឧបករណ៍សម្រាប់ការសិក្សាតាមប្រព័ន្ធអនឡាញ និងកុមារត្រូវធ្វើការដើម្បីជួយទ្រទ្រង់គ្រួសារ)។ ផលវិបាកនៃជំងឺរាតត្បាតនេះនឹងបន្តលេចឡើងក្នុងពេលអនុវត្តយុទ្ធសាស្ត្រប្រចាំប្រទេសថ្មីនេះ។ អង្គការភ្លែនអន្តរជាតិកម្ពុជាយល់ច្បាស់ពីបញ្ហាស្មុគស្មាញទាំងនេះ ហើយនិងឆ្លើយតបដោយផ្តល់ឱកាសសម្រាប់ការសាកសួរ ការលើកឡើងនូវការព្រួយបារម្ភ និងយោបល់ផ្សេងៗ ដើម្បីកែលម្អការអនុវត្តកាន់តែប្រសើរឡើង។



[3] ប្រភព ៖ ការអង្កេតរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជាស្តីពីផលប៉ះពាល់នៃជំងឺកូវីដ ១៩ លើគ្រួសារងាយរងគ្រោះនៅកម្ពុជា ឆ្នាំ ២០២១ (ចេញផ្សាយនៅ ខែឧសភា ឆ្នាំ២០២១) ។

# គោលបំណងរបស់យើង

មហិច្ឆតានៃយុទ្ធសាស្ត្រប្រចាំប្រទេសទី ៤ របស់អង្គការភ្លែនអន្តរជាតិកម្ពុជា (២០២១-២០២៦) គឺក្នុងរយៈពេល ៥ឆ្នាំខាងមុខ អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងបង្កើនកិច្ចសហការក្នុងភាពជាដៃគូយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់សិទ្ធិអំណាចរបស់ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅកម្ពុជា និងលើកស្ទួយសម្លេងនៃភាពចម្រុះផ្សេងគ្នារបស់ពួកគេ ហើយគាំទ្រពួកគេទទួលបានចំណេះដឹង ជំនាញ និងទំនុកចិត្តដែលពួកគេត្រូវការដើម្បីបំពេញបានសិទ្ធិ និងសម្រេចបានសក្តានុពលពេញលេញរបស់ខ្លួន។

នៅឆ្នាំ ២០២៦ យើងមានគោលដៅផ្តោតលើក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅប្រទេសកម្ពុជា ចំនួន ២,៥លាននាក់ (អ្នកទទួលផលផ្ទាល់ចំនួន ១លាននាក់ និងអ្នកទទួលផលដោយប្រយោលចំនួន ១,៥លាននាក់)។



**ដើម្បីសម្រេចគោលដៅនេះ អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងជំរុញការចូលរួមយ៉ាងសកម្មរបស់អ្នកពាក់ព័ន្ធ និងអង្គការដៃគូក្នុងស្រុក ក៏ដូចជាក្រសួងពាក់ព័ន្ធសំខាន់ៗ នៃរាជរដ្ឋាភិបាលកម្ពុជាសំដៅ ៖**

- លើកកម្ពស់សិទ្ធិអំណាចរបស់កុមារ យុវជន និងសហគមន៍ ដើម្បីការផ្លាស់ប្តូរសំខាន់ៗ ដែលអាចដោះស្រាយឫសគល់នៃការរើសអើងលើក្មេងស្រី និងស្ត្រី និងបុព្វហេតុនៃការមិនរាប់បញ្ចូល និងភាពងាយរងគ្រោះជារួម
- ជំរុញឱ្យមានការផ្លាស់ប្តូរការអនុវត្ត និងគោលនយោបាយនៅកម្រិតមូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់សកលតាមរយៈ វិសាលភាពរបស់យើង ចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងដែលកុមារកំពុងជួបប្រទះ
- ធ្វើការជាមួយសហគមន៍ និងកុមារ ដើម្បីត្រៀមខ្លួន ឆ្លើយតប និងជម្នះបញ្ហា និងភាពមិនអនុគ្រោះ
- គាំទ្រកុមារសម្រេចបានវឌ្ឍនភាពប្រកបដោយសុវត្ថិភាព និងភាពជោគជ័យ ចាប់ពីពេលកើតរហូតដល់ពេញវ័យ ដោយបន្តធ្វើការជាមួយមនុស្សវ័យជំទង់ដែលពួកគេនឹងក្លាយជាឪពុកម្តាយនាពេលអនាគត។



# ជំនាញរបស់យើង

អង្គការភ្លែនអន្តរជាតិកម្ពុជា កន្លងមកមានកេរ្តិ៍ឈ្មោះល្អចំពោះស្នាដៃការងារដែលសម្រេចបានជាមួយក្រសួងពាក់ព័ន្ធសំខាន់ៗ ហើយត្រូវបានទទួលស្គាល់ជាដៃគូអភិវឌ្ឍន៍ដែលគួរឱ្យជឿជាក់ និងជាអ្នកអនុវត្តន៍មានសមត្ថភាពទាំងនៅកម្រិតអភិវឌ្ឍន៍គោលនយោបាយ និងកម្រិតអនុវត្តន៍។ ជាមួយគ្នានេះដែរ យើងក៏បង្កើតកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលមានទស្សនវិស័យដូចគ្នា។ អ្វីដែលសំខាន់គឺ អង្គការភ្លែនអន្តរជាតិកម្ពុជា ជាស្ថាប័នអភិវឌ្ឍន៍មួយមានកេរ្តិ៍ឈ្មោះល្បីចំពោះការងារពាក់ព័ន្ធនឹងសិទ្ធិកុមារ កិច្ចការពារកុមារ អាហារូបត្ថម្ភនៅតាមសហគមន៍ ការអប់រំកុមារតូច និងទឹកស្អាត និងអនាម័យ។ អង្គការភ្លែនអន្តរជាតិកម្ពុជា ត្រូវបានគេទទួលស្គាល់កាន់តែច្រើនថាជាអង្គការអភិវឌ្ឍន៍នាំមុខគេមួយ មានភាពលេចធ្លោរ និងជោគជ័យលើការងារយេនឌ័រដែលផ្តោតសំខាន់លើក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង។



# ចំណុចផ្លាស់ប្តូរសំខាន់ៗ ក្នុងយុទ្ធសាស្ត្រប្រចាំប្រទេសថ្មី



# នៅក្នុងយុទ្ធសាស្ត្រប្រចាំប្រទេសថ្មីនេះ ការអនុវត្តមានភាពខុសគ្នាពីយុទ្ធសាស្ត្រប្រចាំប្រទេសលើកមុនចំនួន ៤ ចំណុច៖

**១**

ទី ១ ផ្តោតសំខាន់លើក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង។ ទោះបីយ៉ាងណាក៏ដោយ ក៏ក្មេងប្រុស និងបុរស នៅតែត្រូវបានកំណត់ជាក្រុមគោលដៅដ៏សំខាន់សម្រាប់ការផ្លាស់ប្តូរដើម្បីស្ត្រីនៅប្រទេសកម្ពុជាផងដែរ។ យើងនឹងផ្តោតសំខាន់លើក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងដែលរងការរើសអើងគ្រប់ប្រភេទ ទាក់ទងនឹងសិទ្ធិ និងភាពក្រីក្រពហុវិស័យ រួមទាំង ក្រុមជនជាតិដើមភាគតិច ក្រុមមានពិការភាព និងក្រុមមានទំនោរនិន្នាការស្រឡាញ់ភេទដូចគ្នា។

**២**

ទី ២ យុទ្ធសាស្ត្រនេះផ្លាស់ប្តូរពីរចនាសម្ព័ន្ធនៃការអនុវត្តពីមុន ដែលផ្តោតលើវិស័យជាក់លាក់ មកជាកម្មវិធីស្នូលពហុវិស័យដែលអនុវត្តផ្អែកលើវដ្តជីវិត។

**៣**

ទី ៣ យុទ្ធសាស្ត្រនេះផ្តោតការយកចិត្តទុកដាក់លើដំណើរការផ្ទៃក្នុងរបស់ អង្គការផ្លែនអន្តរជាតិកម្ពុជា រួមទាំងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍ភាពជាអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រ។ យើងនឹងបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតវប្បធម៌វិជ្ជមានដែលចែករំលែកអំណាច លុបបំបាត់ភាពលម្អៀង ជំរុញបរិយាបន្ន និងលើកទឹកចិត្តឱ្យមានស្វ័យថែទាំ និងការយកចិត្តទុកដាក់ចំពោះអ្នកដទៃ។ សកម្មភាពគន្លឹះមួយក្នុងផែនការរៀបចំ គឺត្រូវបន្តការងារនេះដោយការលើកទឹកចិត្តគណៈគ្រប់គ្រងជាន់ខ្ពស់ឱ្យអនុវត្តវប្បធម៌ថ្មី រួចជំរុញវប្បធម៌នេះទៅក្នុងទិដ្ឋភាពនីមួយៗនៃការបំពេញការងារប្រចាំថ្ងៃ ដោយការបញ្ជ្រាបតាមរយៈការរៀបចំប្រតិបត្តិការរបស់ស្ថាប័ន និងការអនុវត្តការងាររបស់បុគ្គលិក។

**៤**

ទី ៤ មានការផ្លាស់ប្តូរតំបន់ភូមិសាស្ត្រគោលដៅ រួមទាំងការផ្តោតលើអន្តរាគមន៍នៅតំបន់ប្រជុំជន។

# ទិដ្ឋភាពរួម នៃយុទ្ធសាស្រ្តប្រចាំប្រទេស

ជម្រើសកម្មវិធីស្នូលទាំង ៤ របស់ អង្គការភ្លែនអន្តរជាតិកម្ពុជា គឺឆ្លុះបញ្ចាំងអំពីអភិក្រមវដ្តជីវិតដែលបំពេញតម្រូវការរបស់ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្រ្តីវ័យក្មេងនៅកម្ពុជា។ ពោលគឺ ជម្រើសដែលកើតចេញពីការវាយតម្លៃជាយុទ្ធសាស្រ្ត បូករួមនឹងការវាយតម្លៃសមត្ថភាពផ្ទៃក្នុង លទ្ធភាព ឱកាសទទួលបានធនធាន និងការគិតគូរពីអាទិភាព និងទស្សនវិស័យជាសកលរបស់អង្គការភ្លែនអន្តរជាតិ។



# កម្មវិធីស្នូលរបស់ អង្គការភ្លែនអន្តរជាតិកម្ពុជា សម្រាប់ឆ្នាំ ២០២១-២០២៦

**ជម្រើសកម្មវិធីស្នូលទាំង ៤ របស់ អង្គការភ្លែនអន្តរជាតិកម្ពុជា គឺឆ្លុះបញ្ចាំងអំពីអភិក្រមវដ្តជីវិតដែលបំពេញតម្រូវការរបស់ក្មេងស្រីជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង នៅកម្ពុជា។ ពោលគឺ ជម្រើសដែលកើតចេញពីការវាយតម្លៃជាយុទ្ធសាស្ត្រ បូករួមនឹងការវាយតម្លៃសមត្ថភាពផ្ទៃក្នុង លទ្ធភាព ឱកាសទទួលបានធនធាន និងការគិតគូរពីអាទិភាព និងទស្សនវិស័យជាសកលរបស់អង្គការភ្លែនអន្តរជាតិ។**

ជម្រើសរបស់អង្គការភ្លែនអន្តរជាតិកម្ពុជាផ្អែកទៅលើភាពចាំបាច់ (ការធ្វើការក្នុងតំបន់ និងជាមួយប្រជាជនដែលមិនទទួលបានឱកាសគ្រប់គ្រាន់) ជំនាញរបស់យើង (សិទ្ធិកុមារ កិច្ចការពារកុមារ ទឹកស្អាតនិងអនាម័យ ការអប់រំកុមារតូច និងទស្សនវិស័យជាសកលរបស់យើង (សមភាពយេនឌ័រ)។ កម្មវិធីស្នូលទាំងនេះនឹងត្រូវបានរួមបញ្ចូលគ្នា (ជាយុទ្ធសាស្ត្រដែលត្រូវបានបង្កើតឡើងដោយបុគ្គលិក និងអ្នកពាក់ព័ន្ធ បើទោះបីជាដំណើរការនៃការអនុវត្តមានការលំបាក ក៏ប៉ុន្តែវានឹងមានប្រសិទ្ធភាពជាងមុន) ដោយផ្អែកលើជំនាញជាក់លាក់របស់ អង្គការភ្លែនអន្តរជាតិកម្ពុជា នៅក្នុងវិស័យអប់រំកុមារតូច ទឹកស្អាតនិងអនាម័យ កិច្ចការពារកុមារ និងជំនាញជាច្រើនរបស់យើងដែលពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិអំណាចរបស់ក្មេងស្រី និងការរៀបចំកម្មវិធីប្រកបដោយទស្សនទានយេនឌ័រ។ បន្ថែមលើនេះ កម្មវិធីស្នូលនីមួយៗ រាប់បញ្ចូលលទ្ធផលមួយសម្រាប់ការងារកិច្ចសហការស្វែងរកមតិគាំទ្រ។ អ្វីដែលសំខាន់នោះគឺ អំឡុង ពេលនៃការអនុវត្តយុទ្ធសាស្ត្រប្រចាំប្រទេសថ្មីនេះនឹងរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ ដូច្នេះហើយអង្គការភ្លែន  អន្តរជាតិកម្ពុជានឹងដោះស្រាយបញ្ហាដែលពាក់ព័ន្ធនានានៅពេលអនុវត្តកម្មវិធីស្នូលទាំងនោះ (ឧ. ត្រូវបានគេប៉ាន់ប្រមាណថា នៅពេលដែលសាលាបើកឡើងវិញ កុមារជាច្រើននឹងមិនត្រលប់ទៅបន្តការសិក្សាវិញទេ ដូច្នេះ អង្គការភ្លែនអន្តរជាតិកម្ពុជានឹងដោះស្រាយបញ្ហាដោយការផ្តល់នូវជម្រើសនៅក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតដើម្បីជួយគ្រួសារក្រីក្រ ជួយដល់ក្រុម/បណ្តាញកុមារ និងយុវជន ក្នុងការរៀបចំយុទ្ធនាការត្រលប់ចូលសាលារៀន និងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកែសម្រួលកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន...)។



# ការចាប់ផ្តើមជាមួយសុខភាពល្អ

**កម្មវិធីស្នូល “ការចាប់ផ្តើមជាមួយសុខភាពល្អ” រួមបញ្ចូលនូវវិស័យសំខាន់ៗ ចំនួន ៣ រួមមាន អាហារូបត្ថម្ភ ការគាំពារនិងអភិវឌ្ឍន៍កុមារតូច និងទឹកស្អាតនិងអនាម័យ និងផ្តោតសំខាន់លើក្រុមឪពុកម្តាយវ័យក្មេង អាយុពី ១៥ ដល់ ២៤ឆ្នាំ និងកូនៗ អាយុក្រោម ៦ឆ្នាំ។**

កម្មវិធីស្នូលនេះមានគោលបំណងគាំទ្រក្មេងស្រី និងក្មេងប្រុសទទួលបាន សុខភាពល្អ អាហារូបត្ថម្ភគ្រប់គ្រាន់ និងឱកាសរៀនសូត្រ និងការអភិវឌ្ឍដំបូងដ៏ល្អប្រសើរតាមរយៈការផ្លាស់ប្តូរឥរិយាបថ និងការផ្លាស់ប្តូរក្នុងសង្គមដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ភាពងាយស្រួលក្នុងការទទួលបានសេវាប្រកបដោយគុណភាព និងការបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល។ សមាសធាតុសំខាន់នៃកម្មវិធីគាំពារនិងអភិវឌ្ឍន៍កុមារតូច គឺផ្តោតលើការគាំទ្រឪពុកម្តាយ/អ្នកថែទាំ ជាពិសេស ការផ្តល់ការបណ្តុះបណ្តាលដល់អ្នកម្តាយវ័យក្មេងស្តីពីការថែបំប៉នដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងការរៀនសូត្រពីដំបូង ក៏ដូចជាការលើកកម្ពស់ការចូលរួមបែបវិជ្ជមានរបស់បុរសក្នុងការអភិវឌ្ឍកុមារតូច។ កម្មវិធី “ការចាប់ផ្តើមជាមួយសុខភាពល្អ” គាំទ្រឱកាសរៀនសូត្រពីដំបូង (មត្តេយ្យសិក្សា) សម្រាប់កុមារអាយុចាប់ពី ៣ឆ្នាំ ដែលគ្រប់គ្រងដោយសហគមន៍ រៀនតាមរយៈការលេង និងឆ្លើយតបនឹងតម្រូវការយេនឌ័រ ហើយនិងការត្រៀមខ្លួនរបស់កុមារតូចសម្រាប់ថ្នាក់បឋមសិក្សា។ សមាសធាតុសំខាន់នៃកម្មវិធីអាហារូបត្ថម្ភ និងការថែទាំសុខភាពមាតា ទារក និងកុមារ គឺធ្វើការជាមួយស្ត្រីដើម្បីពង្រឹងចំណេះដឹង ជំនាញ និងទំនុកចិត្តរបស់ស្ត្រីលើការអនុវត្តការថែទាំសុខភាពសំខាន់ៗ ក៏ដូចជាប្រើប្រាស់ និងទទួលបានសេវាសុខភាព និងអាហារូបត្ថម្ភសម្រាប់ មាតា ទារក និងកុមារ។ កម្មវិធីក៏នឹងធ្វើការជាមួយអង្គការដៃគូ ក្រុមគ្រួសាររបស់កុមារ និងសហគមន៍ ដើម្បីបង្កើនការគាំទ្រសុខភាពមាតា ហើយនិងសហការជាមួយអាជ្ញាធរ/អ្នកផ្តល់សេវាសុខភាព និងបុគ្គលិកសុខភាពសហគមន៍ដើម្បីផ្តល់ការពិគ្រោះយោបល់ និងសេវាសុខភាព និងអាហារូបត្ថម្ភមាតា ទារក កុមារ ប្រកបដោយគុណភាព ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងជំរុញការចូលរួមរបស់បុរស។ សមាសធាតុនៃកម្មវិធីទឹកស្អាត និងអនាម័យ គាំទ្រដល់អន្តរាគមន៍ផ្លាស់ប្តូរឥរិយាបថ និងសង្គមប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនការប្រើប្រាស់បរិក្ខារអនាម័យឱ្យបានកាន់តែទូលំទូលាយនៅតាមសហគមន៍ និងការចែករំលែកការងារទាក់ទងនឹងទឹកស្អាត និងអនាម័យ ការសម្រេចចិត្ត និងការគ្រប់គ្រងមានសមភាពរវាងបុរស និងស្ត្រី។



# កិច្ចការពារជំនាន់ថ្មី

## កម្មវិធីស្នូល “កិច្ចការពារជំនាន់ថ្មី” ផ្តោតសំខាន់លើក្រុមក្មេងស្រី ក្មេងប្រុស និងយុវជន អាយុក្រោម ២៤ឆ្នាំ។

កម្មវិធីគាំទ្រដល់ការរស់នៅ គ្មានអំពើហិង្សា គ្មានការរំលោភបំពាន គ្មានការកេងប្រវ័ញ្ច និងគ្មានការមិនអើពើ ហើយនិងការផ្តល់/ការសម្របសម្រួលការទទួលបានប្រកបដោយគុណភាពខ្ពស់នូវការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និងអាយុ និងការគាំទ្រផ្សេងទៀតពីអង្គការភ្លែនអន្តរជាតិកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាសហគមន៍ និងគ្រួសារ។ កម្មវិធី “កិច្ចការពារជំនាន់ថ្មី” គឺផ្តោតលើសកម្មភាពកិច្ចការពារយ៉ាងទូលំទូលាយប្រឆាំងនឹងអំពើហិង្សានៅគ្រប់កម្រិត តាមរយៈការពង្រឹងសមត្ថភាព និងឥរិយាបថរបស់កុមារ និងយុវជន គ្រួសារ សហគមន៍ និងសង្គមស៊ីវិល និងការកែលម្អក្របខ័ណ្ឌ និងសេវាដែលរួមបញ្ចូលគ្នានៅកម្រិតមូលដ្ឋាន និងថ្នាក់ជាតិ ជាពិសេសការបង្កើនលទ្ធភាពក្នុងការទទួលបានសេវាកិច្ចការពារកុមារដែលសមស្របតាមអាយុសម្រាប់ កុមារ ក្មេងស្រីវ័យជំទង់ ក្មេងប្រុសវ័យជំទង់ និងយុវជនក្រុមមានទំនោរនិន្នាការស្រលាញ់ភេទដូចគ្នា និងកុមារមិនទទួលបានការយកចិត្តទុកដាក់ដែលធ្លាប់ទទួលរងផលប៉ះពាល់នៃ ( និង/ឬប្រឈមនឹង ) អំពើហិង្សា។ ខណៈដែលមានការផ្តោតយ៉ាងច្បាស់លាស់លើការទប់ស្កាត់ និងដោះស្រាយការអនុវត្តដែលបង្កហានិភ័យ ( ឧ. ការរៀបការវ័យក្មេង អំពើហិង្សាផ្អែកលើយេនឌ័រ និងហានិភ័យខ្ពស់នៃអំពើហិង្សា និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ ) កម្មវិធីដែលមានវិសាលភាពធំទូលាយអាចជួយឱ្យអង្គការភ្លែនអន្តរជាតិកម្ពុជា ដោះស្រាយបានគ្រប់ជ្រុងជ្រោយនូវលក្ខណៈវិនិច្ឆ័យជុំវិញអំពើហិង្សាគ្រប់ទម្រង់។ អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងពង្រឹងការយល់ដឹង និងសមត្ថភាពរបស់គ្រួសារ ស្របពេលជាមួយគ្នានេះដែរនឹងមានការកៀរគរ និងគាំទ្រដល់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ក្នុងការស្វែងរកមតិគាំទ្រលើការផ្លាស់ប្តូរឆ្ពោះទៅរកឥរិយាបថអហិង្សា និងកាន់តែមានសមភាពនៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។ កិច្ចសហការស្វែងរកមតិគាំទ្រនឹងតស៊ូមតិជាមួយអ្នកធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតដើម្បីការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ហើយការពារកុមារ និងយុវជន ជាពិសេស ក្មេងស្រី ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងពីអំពើហិង្សាគ្រប់ទម្រង់។



# រៀនមួយជីវិត

## កម្មវិធីស្នូល “រៀនមួយជីវិត” ផ្តោតសំខាន់លើក្រុមក្មេងស្រី ក្មេងប្រុស និងយុវជន អាយុពី ៦ ដល់ ២៤ឆ្នាំ។

កម្មវិធីគាំទ្រដល់ការអភិវឌ្ឍជំនាញទន់ និងជំនាញឯកទេសដែលចាំបាច់សម្រាប់ការប្រើប្រាស់នៅក្នុងការប្រកបការងារ រួមមាន ការអប់រំប្រកបដោយគុណភាព និងមានបរិយាបន្ន ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បំណិនជីវិត សហគ្រិនភាព។ល។ ដើម្បីការងារទទួលបានប្រាក់ឈ្នួល និងការប្រកបរបររកស៊ីដែលផ្តល់ប្រាក់ចំណេញ និងរួមបញ្ចូលសុខភាពបន្តពូជ និងសិទ្ធិ។

កម្មវិធីស្នូលនេះផ្តល់ដល់ ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង នូវលទ្ធភាពពេញលេញក្នុងការទទួលបានការអប់រំ និងការអភិវឌ្ឍជំនាញប្រកបដោយគុណភាពគ្រប់គ្រាន់ដែលជំរុញ និងគាំទ្រដល់ការសិក្សាពេញមួយជីវិត និងមានការងារសមរម្យ។ សកម្មភាពនៃកម្មវិធីនេះនឹងផ្តោតលើការកែលម្អគុណភាពនៃការបង្រៀន និងការរៀនសូត្រតាមរយៈការបង្កើនសមត្ថភាព និងការប្តេជ្ញាចិត្តរបស់គ្រូបង្រៀន និងតួអង្គអប់រំផ្សេងទៀតឱ្យអនុវត្តវិធីសាស្ត្រនៃការបង្រៀនដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងកម្មវិធីសិក្សាមានបរិយាបន្នដែលផ្តោតការយកចិត្តទុកដាក់លើអ្នកសិក្សា ការសិក្សាផ្នែកសង្គម និងផ្លូវចិត្ត/ការគាំទ្រផ្នែកចិត្តសង្គម។ កម្មវិធីនេះផងដែរនឹងគាំទ្រសាលារៀនជាទីកន្លែងទទួលបានចំណេះដឹង ត្រូវបានការពារ និងមានសុវត្ថិភាព (ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ) ហើយនិងផ្តល់នូវបរិក្ខារដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងមានបរិយាបន្ន រួមមាន បរិក្ខារទឹកស្អាតនិងអនាម័យ និងការរក្សាអនាម័យនៅពេលមករដូវ រួមទាំងការដាក់បញ្ចូលការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយទៅក្នុងកម្មវិធីសិក្សា និងការបង្កើនសមត្ថភាពរបស់គ្រូបង្រៀនអំពីប្រសិទ្ធភាពនៃការរៀន និងបង្រៀន។ ផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពបង្ហាញថា នៅតំបន់គោលដៅ ការបោះបង់ការសិក្សា និងកុមារ និងយុវជនក្រៅសាលា នៅតែមានអត្រាខ្ពស់។ ដើម្បីឱ្យក្មេងស្រី ក្មេងប្រុស និងយុវជនត្រលប់ចូលរៀនវិញ កម្មវិធីនេះនឹងពង្រឹងយន្តការចូលរៀន/ចូលរៀនឡើងវិញ រួមមាន ថ្នាក់ពន្លឿនការអប់រំ គាំទ្រការអភិវឌ្ឍ និងគុណភាពនៃឱកាសអប់រំជាជម្រើស ក៏ដូចជាលើកកម្ពស់ និងគាំទ្រគំនិតផ្តួចផ្តើមអប់រំដឹកនាំដោយសហគមន៍។ កម្មវិធីស្នូលនេះនឹងពង្រឹងអភិបាលកិច្ចសាលារៀន ដើម្បីបង្កើនការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព និងមានបរិយាបន្ន (ឧ. ការជំរុញការចូលរួមរបស់មាតាបិតាសិស្ស និងអ្នកដឹកនាំ) និងអនុវត្តសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រនៅក្នុងការបង្កើតគោលនយោបាយដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងមានបរិយាបន្ននៅកម្រិតមូលដ្ឋាន និងថ្នាក់ជាតិ ហើយនិងកសាងសម្ព័ន្ធភាព និងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព ព្រមទាំងលើកកម្ពស់ និងគាំទ្រគណនេយ្យភាពបែបចូលរួមនៅក្នុងសាលារៀន។



## កម្មវិធី “ជំនាញ និងឱកាសការងារយុវជន និងសហគ្រិនភាព”

កម្មវិធីគាំទ្រក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងដែលមិនកំពុងសិក្សា។ កម្មវិធីនេះផ្តោតលើក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ដើម្បីអភិវឌ្ឍបំណិនជីវិតរបស់ពួកគេ រួមមាន សុខភាពបន្តពូជ និងសិទ្ធិ និងសមត្ថភាពអនុវត្តការងារ និង/ឬសហគ្រិនភាព។

ស្ត្រីវ័យក្មេងគឺជាតួអង្គដ៏សំខាន់នៃកម្មវិធីនេះ ដូច្នេះហើយអង្គការភ្លែនអន្តរជាតិកម្ពុជានឹងសហការជាមួយវិស័យឯកជនដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ។ គោលបំណងនៃការសហការនេះគឺដើម្បីផ្សារភ្ជាប់ស្ត្រីវ័យក្មេងទៅនឹងព័ត៌មានទីផ្សារ និងឱកាសការងារ ព្រមទាំងលើកកម្ពស់បរិយាកាសឆ្លើយតបនឹងតម្រូវការយេនឌ័រសម្រាប់ស្ត្រីវ័យក្មេងដែលអាចឱ្យពួកគេជ្រើសរើសអាជីពទៅតាមបំណងប្រាថ្នារបស់ខ្លួន។ អង្គការភ្លែនអន្តរជាតិកម្ពុជា នៅតែគាំទ្ររាជរដ្ឋាភិបាលនៅក្នុងការចូលរួមអភិវឌ្ឍសហគ្រិនឌីជីថល និងវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងទៀត ដើម្បីផ្តល់ជំនាញបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់ផលិតភាព។



# ភាពដឹកនាំរបស់ក្មេងស្រី

## កម្មវិធីស្នូល “ភាពដឹកនាំរបស់ក្មេងស្រី” ផ្តោតសំខាន់លើក្រុមក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង អាយុពី ១២ ដល់ ២៤ឆ្នាំ។

កម្មវិធីលើកកម្ពស់សមត្ថភាពរបស់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ព្រមទាំងក្មេងប្រុសវ័យជំទង់ និងបុរសវ័យក្មេង តាមរយៈការបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ភាពអង់អាច និងភាពជាអ្នកដឹកនាំ ភាពជាពលរដ្ឋសកម្ម និងការចូលរួមជាពលរដ្ឋក្នុងនាមជាបុគ្គល ឬ ក្រុម ដើម្បីកសាង និងប្រើប្រាស់ភ្នាក់ងារ បណ្តាញ និងធនធានរបស់ពួកគេក្នុងការផ្លាស់ប្តូរវិសមភាពនៃទំនាក់ទំនងអំណាច។ ការគាំទ្រយុវជនគឺជាចំណុចដ៏សំខាន់ដើម្បីធានាថា កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេគឺអាចពង្រឹងសមត្ថភាព និងការអភិវឌ្ឍសហគមន៍ ការសម្រេចបានគោលបំណង និងសមត្ថភាពក្នុងការរៀបចំជីវិតផ្ទាល់ខ្លួន និងតថភាពសង្គម។ កម្មវិធីនេះនឹងសហការជាមួយបណ្តាញផ្សព្វផ្សាយព័ត៌មាន ដើម្បីផ្សព្វផ្សាយសំឡេង និងចំណាប់អារម្មណ៍របស់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង និងធ្វើការជាមួយគ្រួសារ និងសហគមន៍របស់ពួកគេ ដើម្បីគាំទ្រ និងការពារយុវជន និងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការជំរុញការផ្លាស់ប្រែក្នុងសង្គម និងលើកកម្ពស់សមភាព។



# បម្រែបម្រួលអាកាសធាតុ

**ក្រៅពីកម្មវិធីស្នូលទាំង ៤ នេះ អន្តរាគមន៍ទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ ភាពធន់នឹងអាកាសធាតុ និងនិរន្តរភាពបរិស្ថាន នឹងក្លាយជាប្រធានបទអន្តរវិស័យនៅក្នុងកម្មវិធីទាំងអស់របស់អង្គការភ្លែនអន្តរជាតិកម្ពុជា ជាពិសេស កម្មវិធីរៀនមួយជីវិត និងកម្មវិធីភាពដឹកនាំរបស់ក្មេងស្រី។**

ការឆ្លើយតបគ្រោះមហន្តរាយធ្ងន់ធ្ងរនឹងប្រើប្រាស់ជំនាញតាមកម្មវិធី និងទំនាក់ទំនងរវាងកម្មវិធីដែលមានស្រាប់ ជាពិសេស កម្មវិធីទឹកស្អាតនិងអនាម័យ និងកម្មវិធីកិច្ចការពារ។ ការឆ្លើយតបនេះនឹងផ្អែកលើបទពិសោធន៍កន្លងមកនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅកម្ពុជា ព្រមទាំងជំនាញដែលមាន តាមរយៈបណ្ដាញគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយរបស់អង្គការភ្លែនអន្តរជាតិនៅតំបន់អាស៊ីប៉ាស៊ីហ្វិច។ ក្រៅពីនេះ អង្គការភ្លែនអន្តរជាតិកម្ពុជា មានក្រុមឆ្លើយតបគ្រោះអាសន្ន និងផែនការត្រៀមបម្រុងគ្រោះមហន្តរាយដែលត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ។



# ហេតុអ្វីបានជាយើងមានវត្តមាន នៅទីនេះ ?

ដើម្បីសម្រេចបានទស្សនវិស័យ និងគោលដៅរបស់យើង យើងបានកំណត់យក **ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង** ជាក្រុមគោលដៅ។ យើងនឹងផ្តោតសំខាន់លើក្រុមគោលដៅដែលរងគ្រោះដោយសារការរើសអើងគ្រប់ប្រភេទទាក់ទងនឹងសិទ្ធិ និងភាពក្រីក្រពហុវិស័យ ជាពិសេស **ក្រុមក្មេងស្រីដែលត្រូវបានឪពុកម្តាយទុកចោល** និងប្រឈមនឹង **ការរើសអើង** រួមមាន ក្រុមជនជាតិដើមភាគតិច អ្នករស់នៅក្នុងតំបន់ភូមិសាស្ត្រជួបការលំបាក ក្រុមមានអត្តសញ្ញាណគ្រួសារក្រីក្រនៅទីជនបទ និងទីប្រជុំជន ក្រុមមានពិការភាព និងក្រុមមានទំនោរនិន្នាការស្រឡាញ់ភេទដូចគ្នា។

ក្រៅពីនេះ អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងកសាងសមត្ថភាពផ្នែកបច្ចេកទេស និងសមត្ថភាពអនុវត្តន៍របស់ **អង្គការដៃគូយុទ្ធសាស្ត្រ** (អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក) ក៏ដូចជា **អង្គការសង្គមស៊ីវិល** រួមមាន ក្លឹបយុវជន និងបណ្តាញយុវជន។ ក្រៅពីនេះ អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងសហការយ៉ាងជិតស្និទ្ធជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលមានទស្សនវិស័យដូចគ្នា ដោយការរួមគ្នាខិតខំប្រឹងប្រែងនៅក្នុងកិច្ចសហការស្វែងរកមតិគាំទ្រទៅលើគោលនយោបាយ និងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់ផលប្រយោជន៍កាន់តែប្រសើរឡើងដល់ប្រជាជន និងតំបន់ជួបការលំបាក និងមិនទទួលបានសេវាគ្រប់គ្រាន់។

តាមរយៈការជំរុញការចូលរួម និងគាំទ្ររបស់ខ្លួនជាមួយ **ក្រសួងសាម៉ី និងស្ថាប័នពាក់ព័ន្ធចម្រុះក្នុងជួររាជរដ្ឋាភិបាល** (ជាពិសេស ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកិច្ចការនារី) អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងលើកកម្ពស់ការយល់ដឹង និងសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធទាំងនោះ។



# ការវិភាគស្ថានភាព

ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយនៅតំបន់អាស៊ីអាគ្នេយ៍ដែលមានប្រជាជនវ័យក្មេងអាយុក្រោម ២៥ឆ្នាំ មានចំនួនពាក់កណ្តាលនៃចំនួនប្រជាជនសរុប ១៦,៥លាននាក់ ហើយប្រជាជនអាយុក្រោម ១៥ឆ្នាំ មានចំនួន ១/៣ (តួលេខឆ្នាំ ២០១៩)។ ប្រជាជនកម្ពុជាមួយភាគធំជាជនជាតិខ្មែរ (៩៧,៦%)។ ក្រៅពីនេះ មានក្រុមជនជាតិដើមភាគតិចផ្សេងៗគ្នាចំនួន ២៤ក្រុម ដែលស្មើនឹង ២% នៃចំនួនប្រជាជនសរុបនៅកម្ពុជា។ ជនជាតិដើមភាគតិចទាំងអស់នោះរស់នៅក្នុងខេត្ត ៤ ដែលក្នុងចំណោមខេត្តទាំង ៤ នោះ ខេត្តរតនគិរី និងស្ទឹងត្រែង ជាតំបន់ប្រតិបត្តិកម្មវិធីរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា។



ចាប់ពីឆ្នាំ ១៩៩៥ រហូតដល់ ឆ្នាំ២០១៧ ភាពក្រីក្របានថយចុះពី ៤៧,៨% មកត្រឹម ១៣,៥% [4] ហើយកម្ពុជាបានវិវឌ្ឍខ្លួនទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០១៦។ ការប្រែក្លាយពីសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យឧស្សាហកម្ម និងសេវាកម្ម បានធ្វើឱ្យមានការអភិវឌ្ឍនគរូបនីយកម្មយ៉ាងឆាប់រហ័ស និងការធ្វើចំណាកស្រុកយ៉ាងច្រើនទាំងនៅក្នុង និងក្រៅប្រទេស។ ទោះបីជាភាពក្រីក្រជារួមបានថយចុះតាំងពីមុនវិបត្តិជំងឺកូវីដ ១៩ ក៏ដោយ ក៏ប្រជាជនកម្ពុជាចំនួន ៤,៥លាននាក់ នៅតែប្រឈមនឹងភាពក្រីក្រ សូម្បីតែក្នុងករណីមានវិបត្តិសង្គមសេដ្ឋកិច្ច ឬ វិបត្តិធម្មជាតិតិចតួចក្តី។ ការចែករំលែកអត្ថប្រយោជន៍ពីភាពរីកចម្រើនដោយគ្មានសមធម៌ បានធ្វើឱ្យក្រុមកុមារជួបការលំបាកទាក់ទងនឹងយេនឌ័រ ភូមិសាស្ត្រ សមត្ថភាព និងជាតិពន្ធុ/ភាសា។ នៅក្នុងវិបត្តិជំងឺកូវីដ ១៩ នាពេលបច្ចុប្បន្ននេះ បានធ្វើឱ្យសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះយ៉ាងខ្លាំង ហើយចំនួនប្រជាជនក្រីក្រកាន់តែមានការកើនឡើង។

# ក្របខ័ណ្ឌគោលនយោបាយ

យុទ្ធសាស្ត្រប្រចាំប្រទេសថ្មីរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា ស្វែងរកការគាំទ្រមតិបែបស្ថាបនា និងបន្ស៊ីគ្នាជាមួយនឹងអាទិភាពសម្រាប់ការអភិវឌ្ឍថ្នាក់ជាតិ [5]។ អង្គការភ្លែនអន្តរជាតិកម្ពុជា គាំទ្រគោលដៅនៃផែនការសកម្មភាពជាតិរបស់ ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីសុខភាពសិក្សា ដែលរួមបញ្ចូលការផ្តោតលើការរក្សាអនាម័យនៅពេលមករដូវ និងសុខភាពបន្តពូជ និងសិទ្ធិ។
អង្គការភ្លែនអន្តរជាតិកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតគោលនយោបាយជាតិស្តីពី ប្រព័ន្ធកិច្ចការពារកុមារ ហើយបច្ចុប្បន្នកំពុងសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្នុងការបង្កើត និងផ្សព្វផ្សាយយន្តការសម្របសម្រួល។ អង្គការភ្លែនអន្តរជាតិកម្ពុជា បានគាំទ្រផែនការសកម្មភាពជាតិរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញដែលត្រូវបានអនុម័តនៅឆ្នាំ ២០២០។ អង្គការភ្លែនអន្តរជាតិកម្ពុជា បានធ្វើការងារយ៉ាងសកម្មជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្នុងការតាក់តែងច្បាប់ស្តីពីកិច្ចការពារកុមារ និងប្រព័ន្ធមូលដ្ឋាននៃយន្តការការពារកុមារតាមសហគមន៍។

បើទោះបីជារាជរដ្ឋាភិបាលប្តេជ្ញាចិត្តក្នុងការសម្រេចបានសមភាពយេនឌ័រក៏ដោយ ក៏នៅមានភាពជាតំណាងស្ត្រីតិចតួចចំពោះមុខតំណែងនៃគ្រប់កម្រិតនៅក្នុងស្ថាប័នរដ្ឋាភិបាល ហើយនិងមុខតំណែងជ្រើសតាំង។
**នៅឆ្នាំ ២០១៩ ស្ត្រីកាន់មុខតំណែង ១១ អាសនៈក្នុងចំណោម ៦២ អាសនៈនៃព្រឹទ្ធសភា (១៧,៧%) និង ២៥ អាសនៈក្នុងចំណោម ១២៥ អាសនៈនៃរដ្ឋសភា (២០%)** [6]។ ចំនួនស្ត្រីក្នុងក្រុមប្រឹក្សាឃុំប្រែប្រួលតាំងពីឆ្នាំ២០០៧។ នៅឆ្នាំ ២០១៧ ចំនួនស្ត្រីក្នុងក្រុមប្រឹក្សាឃុំគឺត្រឹមតែ ១៦,៨% ប៉ុណ្ណោះ [7]។ សូចនាករនៃភាពជាតំណាងតិចតួចរបស់ស្ត្រីក្នុងតួនាទីអំណាចផ្លូវការ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈភាពខុសគ្នានៃការទទួលបាននៅក្នុងទិដ្ឋភាពរស់នៅរបស់ស្ត្រីក្នុងប្រទេសកម្ពុជា រួមមាន សិទ្ធិគ្រួសារ សង្គម ការអប់រំ សេដ្ឋកិច្ច សិទ្ធិផ្លូវច្បាប់។

**នៅឆ្នាំ ២០១៩
ស្ត្រីកាន់មុខតំណែង ១១
អាសនៈក្នុងចំណោម ៦២
អាសនៈនៃព្រឹទ្ធសភា
(១៧,៧%) និង ២៥ អាសនៈ
ក្នុងចំណោម ១២៥
អាសនៈនៃរដ្ឋសភា(២០%)។**

---

[4] ប្រជាជនកម្ពុជាចំនួន ៣៥% នៅតែរស់នៅក្រោមបន្ទាត់ភាពក្រីក្រអន្តរជាតិ (១,៩០ ដុល្លារសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ) (UNDP ២០១៨)។

[5] ការអនុម័តផែនការសកម្មភាពជាតិត្រូវបានពន្យារពេលដោយសារជំងឺកូវីដ ១៩។ បច្ចុប្បន្ន ផែនការនេះត្រូវបានរំពឹងថានឹងអនុម័តនៅឆ្នាំ ២០២១។

[6] ប្រភពឯកសារ ៖ Women and political leadership in Cambodia – literature review, https://iwda.org.au/assets/files/Women-and-Political-Leadership-in-Cambodia-Literature-Review.pdf។ គួរកត់សម្គាល់ថា នៅឆ្នាំ ២០១៩ កម្ពុជាឈរនៅលេខរៀងទី ១០៧ ក្នុងចំណោម ១៩៣ ប្រទេស ពាក់ព័ន្ធនឹងភាពជាតំណាងរបស់ស្ត្រីក្នុងនយោបាយជាតិ ថយពីលេខរៀងទី ៩៦ នៅឆ្នាំ ២០១៨។

[7] Ibid.

# ស្ថានភាពសិទ្ធិកុមារ និងសិទ្ធិក្មេងស្រី

កុមារស្ថិតក្នុងចំណោមក្រុមដែលងាយរងគ្រោះបំផុតនៅកម្ពុជា។ អត្រាមានជំងឺ និងមរណភាពកុមារក្នុងប្រទេសកម្ពុជានៅមានកម្រិតខ្ពស់ជាងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់ ហើយមានភាពខុសគ្នាខ្លាំងទៅតាមតំបន់។ អត្រាក្រិសក្រិនថ្នាក់ជាតិក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំ មិនមានការប្រែប្រួល ដោយនៅរក្សាអត្រាប្រហែល ៣២% ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ និងបង្ហាញពីគម្លាតសមធម៌៖ បញ្ហាក្រិសក្រិនច្រើនតែកើតមាននៅទីជនបទ (៣៤%) ជាងនៅទីប្រជុំជន (២៤%)។

នៅឆ្នាំ ២០១៥ កុមារមានអាយុ ០-១៧ឆ្នាំ ប្រហែល ១៦% រស់នៅក្រោមបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ។ ប្រមាណ ៧២% នៃកុមារកម្ពុជាដែលមានអាយុ ០-១៧ឆ្នាំ រងគ្រោះដោយសារភាពក្រីក្រពហុសមាសភាគនៅក្នុងវិសាលគមទាក់ទងនឹងផ្នែក អាហារូបត្ថម្ភ សុខភាព ការអភិវឌ្ឍកុមារតូច ការអប់រំផ្លូវការ ទឹកស្អាតនិងអនាម័យ លំនៅដ្ឋាន និងព័ត៌មាន[8]។

កុមារកម្ពុជាជាងពាក់កណ្តាលតែងតែទទួលរងនូវទម្រង់មួយចំនួននៃអំពើហិង្សាផ្លូវកាយនៅក្នុងផ្ទះ  មុនពេលពួកគេឈានចូលដល់វ័យ ១៨ឆ្នាំ។ គ្រូបង្រៀនជាអ្នកបង្កអំពើហិង្សាផ្លូវកាយញឹកញាប់ជាងគេនៅក្រៅផ្ទះ ទោះបីជាទណ្ឌកម្មលើរូបរាងកាយជាអំពើខុសច្បាប់ក្តី។ **កុមារដែលមានទំនោរផ្លូវភេទ អត្តសញ្ញាណភេទ និងការបង្ហាញអត្តសញ្ញាណភេទ និងលក្ខណៈភេទផ្សេងៗ** ប្រឈមនឹងបញ្ហានានាក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួននៅក្នុងគ្រួសារ សហគមន៍ និងសាលារៀន។ គ្មានការការពារផ្លូវច្បាប់ប្រឆាំងនឹងការរើសអើង និងអំពើហិង្សាទៅលើក្រុមដែលមានទំនោរនិន្នាការស្រលាញ់ភេទដូចគ្នាឡើយ។ តាំងពីមុនវិបត្តិជំងឺកូវីដ១៩ កុមារអាយុ ៥-១៧ឆ្នាំ ចំនួន ១៧% បានប្រឡូកក្នុង **ពលកម្មកុមារ។** តួលេខនេះអាចនឹងមានការកើនឡើងខ្លាំងដោយសារវិបត្តិនៃជំងឺកូវីដ១៩។ ក្រៅពីភាពក្រីក្រ និងបទដ្ឋានសង្គមវប្បធម៌ កម្សោយនៃសេវាកិច្ចការពារ និងសុខុមាលភាពកុមារ និងកម្សោយនៃច្បាប់ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ **ធ្វើឱ្យកុមារងាយរងគ្រោះទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទដែលរួមបញ្ចូលការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។**
ដោយសារគ្រូមានសមត្ថភាពនៅមានចំនួនកំណត់ ហើយគុណភាពនៃបរិស្ថានរៀនសូត្រនៅមានកម្រិតទាប ដូច្នេះហើយបានជាអត្រាចុះឈ្មោះចូលរៀននៅក្នុងកម្មវិធីអប់រំកុមារតូច( កម្រិតមត្តេយ្យសិក្សា ) របស់កុមារអាយុ ៣-៥ឆ្នាំ មានត្រឹមតែ ៤0% ប៉ុណ្ណោះ។
អត្រាចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សាមានចំនួនប្រហាក់ប្រហែលនឹងអត្រាចុះឈ្មោះចូលរៀនជាសកល ដោយមានយុគភាពយេនឌ័រ ប៉ុន្តែមានអត្រាខ្ពស់នៃការបោះបង់ការសិក្សាចំពោះសិស្សថ្នាក់ទី ៦។ ជារួម មានសិស្សប្រុសកាន់តែច្រើនរៀនត្រួតថ្នាក់។

**៧២%**

**នៃកុមារកម្ពុជាដែលមានអាយុ ០-១៧ឆ្នាំ រងគ្រោះដោយសារភាពក្រីក្រពហុសមាសភាគនៅក្នុងវិសាលគមទាក់ទងនឹងផ្នែក អាហារូបត្ថម្ភ សុខភាព ការអភិវឌ្ឍកុមារតូច ការអប់រំផ្លូវការ ទឹកស្អាត និងអនាម័យ លំនៅដ្ឋាន និងព័ត៌មាន ។**

[8] UNICEF. (2018). Child Poverty in Cambodia.  Ministry of Planning, SPRI, UNICEF:  Phnom Penh, Cambodia.

ការអប់រំគ្រប់កម្រិតមានគុណភាពទាប ដែលធ្វើឱ្យកុមារជាច្រើនមិនទទួលបានស្តង់ដាររៀនសូត្រសមស្របតាមអាយុ រួមទាំងអក្ខរភាព និងលេខនព្វន្តកម្រិតមូលដ្ឋាន។ អត្រាចុះឈ្មោះចូលរៀនសរុបនៅកម្រិតមធ្យមសិក្សាបឋមភូមិសម្រាប់ក្មេងប្រុសគឺ ៥៦,៥% និងក្មេងស្រី ៤៥,៣% ដោយអត្រាបោះបង់ការសិក្សានៅកម្រិតនេះដែរមានចំនួន ២០%។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិមានកម្រិតទាបសម្រាប់ក្មេងស្រី (២៤,៤%) និងថយចុះសម្រាប់ក្មេងប្រុស (២០,១%)។ សិស្សកម្រិតមធ្យមសិក្សាដែលចុះឈ្មោះចូលរៀនវគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានចំនួនត្រឹមតែ ២% ប៉ុណ្ណោះ [៩] ។ បញ្ហាប្រឈមសម្រាប់សិស្សក្នុងវិស័យនេះគឺពាក់ព័ន្ធនឹងលទ្ធភាពទទួលបានសេវាអប់រំ គុណភាព សមត្ថភាពស្ថាប័ន និងទិដ្ឋភាពសង្គម។

នៅពេលក្មេងស្រីឈានដល់វ័យជំទង់ សិទ្ធិសេរីភាពក្នុងការដើរហើរ និងការទទួលបានឱកាសរបស់ពួកគេត្រូវបានរឹតត្បិតដោយសារការព្រួយបារម្ភពីសន្តិសុខផ្ទាល់ខ្លួន គុណតម្លៃសង្គម និងបទដ្ឋានប្រពៃណី។ បទដ្ឋានទាំងនេះរារាំងសមត្ថភាពរបស់ក្មេងស្រីក្នុងការសម្រេចបានសក្តានុពលពេញលេញរបស់ពួកគេ។ យុវជន ហើយនិងមនុស្សពេញវ័យទាំងពីរភេទនៅតែប្រកាន់ឥរិយាបថគ្មានសមធម៌យេនឌ័រ។ ឧ. អំពើហិង្សាដែលកើតឡើងទៅលើប្តី ឬ ប្រពន្ធ ត្រូវបានទទួលយកដោយស្ត្រី  និងបុរស ថាជាផ្នែកមួយនៃទំនាក់ទំនងអំណាចផ្អែកលើយេនឌ័រ។

ក្នុងចំណោមស្ត្រី ៥នាក់ មានម្នាក់ទទួលរងអំពើហិង្សាផ្លូវកាយ ឬ អំពើហិង្សាផ្លូវភេទពីដៃគូស្និទ្ធស្នាល។ ស្ត្រីនៅទីជនបទទទួលរងអំពើហិង្សាផ្លូវកាយច្រើនជាងស្ត្រីនៅទីប្រជុំជន។ វិសមធម៌លេចឡើងនៅគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅរបស់ស្ត្រីក្នុងប្រទេសកម្ពុជា។ ឧ. ការចូលរួមរបស់ស្ត្រីក្នុងកម្លាំងពលកម្មទទួលបានប្រាក់ឈ្នួលគឺ ៨១,២%  ចំណែកការចូលរួមរបស់បុរសគឺ ៨៨,៧%។ អយុត្តិភាពយេនឌ័រសម្រាប់ការងារទទួលបានប្រាក់ឈ្នួល និងការងារមិនទទួលបានប្រាក់ឈ្នួល រួមចំណែកដល់វិសមភាពយេនឌ័រ និងភាពក្រីក្ររបស់ស្ត្រី និងក្មេងស្រី។

**ការអប់រំគ្រប់កម្រិតមានគុណភាពទាប ដែលធ្វើឱ្យកុមារជាច្រើនមិនទទួលបានស្តង់ដាររៀនសូត្រសមស្របតាមអាយុ រួមទាំងអក្ខរភាព និងលេខនព្វន្តកម្រិតមូលដ្ឋាន។**

បញ្ហាសុខភាពបន្តពូជ និងសិទ្ធិ គឺជាក្តីកង្វល់សម្រាប់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងគ្រប់រូបនៅទូទាំងប្រទេស។ ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងធាប់ប្រឡូកក្នុងការរួមភេទអាយុ ១៥-១៩ឆ្នាំ ចំនួន ៩៥,៤% បានលើកឡើងថាពួកគេមិនប្រើប្រាស់មធ្យោបាយពន្យារកំណើតណាមួយឡើយ។

ការមានផ្ទៃពោះនៅវ័យក្មេង (អាយុ ១៥-១៩ឆ្នាំ) កើនដល់ ១២% នៅឆ្នាំ ២០១៤។ នៅខេត្តរតនគិរី ក្មេងស្រីសម្រាលកូនចំនួន ១៦% មានអាយុ ១២-១៧ឆ្នាំ។ ហេតុដូច្នេះហើយ យុទ្ធសាស្រ្តទប់ស្កាត់គួរផ្តោតលើក្មេងប្រុស និងក្មេងស្រីតាំងពីមុនពេលពួកគេចូលដល់អាយុពេញវ័យ។

[៩] ធៀបនឹងអត្រា ១៨% នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច។

# ការអភិវឌ្ឍយុវជន

**៣១%**

**មានការងារធ្វើត្រូវទៅតាមគុណវុឌ្ឍិភាពរបស់ខ្លួន។ ចំនួនស្ត្រីវ័យក្មេងដែលមានគុណវុឌ្ឍភាពមិនគ្រប់គ្រាន់គឺមានចំនួនច្រើនជាងបុរស។**

យុវជនម្នាក់ក្នុងចំណោមយុវជន ៥នាក់ ត្រូវបានបាត់បង់វិមាត្រសុខុមាលភាព ២ ឬ ច្រើន រួមមាន សុខភាព ការងារ ការអប់រំ និងការចូលរួមក្នុងនាមជាពលរដ្ឋ។ ទោះបីជាចំនួនយុវជនដែលមិនមានការងារធ្វើមិនទទួលបានការអប់រំ ឬ មិនទទួលបានការបណ្តុះបណ្តាលថយចុះពី ៨,៨% នៅឆ្នាំ ២០០៤ មកត្រឹម ៦,៤% នៅឆ្នាំ ២០១៤ ក្តី ក៏យុវជនជាច្រើននៅតែមានភាពអសកម្ម ក្នុងសកម្មភាពសេដ្ឋកិច្ច ដោយសារតែកង្វះមូលធនសង្គម បញ្ហាសុខភាព ឬ គុណវុឌ្ឍិភាពមិនគ្រប់គ្រាន់។ នៅឆ្នាំ ២០១៤ យុវជនក្នុងគ្រួសារប្រកបរបរកសិកម្ម និង/ឬ ក្នុងបញ្ចភាគនៃគ្រួសារក្រីក្របំផុតមិនមានការងារធ្វើ មិនទទួលបានការអប់រំ ឬ មិនទទួលបានការបណ្តុះបណ្តាលមានចំនួនច្រើនបំផុត ដែលក្នុងចំណោម យុវជនទាំងនោះ យុវតីមានប្រហែល ៨៣%។ ការប្រទ្បូកក្នុងកម្លាំងពលកម្មដោយស្ត្រី និងបុរសវ័យក្មេងអាយុ ១៥-១៩ឆ្នាំ មានចំនួន ១១% និងអាយុ ២០-២៤ឆ្នាំ មានចំនួន ១៧%។ យុវជនចំនួន ៣១% មានការងារធ្វើត្រូវទៅតាមគុណវុឌ្ឍិភាពរបស់ខ្លួន។ ចំនួនស្ត្រីវ័យក្មេងដែលមានគុណវុឌ្ឍភាពមិនគ្រប់គ្រាន់គឺមានចំនួនច្រើនជាងបុរស។

# និន្នាការវិវត្តន៍ថ្មីៗ

**បរិបទសេដ្ឋកិច្ចសង្គម** នៅកម្ពុជា រួមបញ្ចូលកត្តានានាជាច្រើន ដូចជា ការធ្វើចំណាកស្រុក បម្រែបម្រួលអាកាសធាតុ ទេសចរណ៍ និងបច្ចេកវិទ្យា ដែលផ្តល់ឱកាសយ៉ាងច្រើនមហាសាលសម្រាប់ការកែលម្អគុណភាពជីវិត ប៉ុន្តែក៏រួមចំណែកធ្វើឱ្យកុមារងាយរងគ្រោះ និងទទួលរងការកេងប្រវ័ញ្ចផងដែរ។ ករណីកាន់តែច្រើននៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញគឺជាកង្វល់ដ៏ធំ ពីព្រោះថា បើទោះបីជាមានសន្ទុះគោលនយោបាយក្នុងការប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញក៏ដោយ ក៏មិនទាន់មានរចនាសម្ព័ន្ធទទួលខុសត្រូវចំពោះកិច្ចការអនុវត្តគោលនយោបាយនៅឡើយទេ។

**ជំងឺកូវីដ ១៩ អាចកំណត់ជា "និន្នាការវិវត្តន៍ថ្មីៗ"** ពីព្រោះជំងឺនេះនឹងបន្តដាក់កំហិតលើជីវិតរស់នៅ និងឱកាសសម្រាប់ប្រជាជនក្រីក្រ និងជួបការលំបាកបំផុតនៅកម្ពុជានាពេលអនាគត ។[10]

ជំងឺកូវីដ ១៩ បានធ្វើឱ្យ **គុណភាពនៃការអប់រំមានកម្រិតទាប** រយៈពេលជាច្រើនទសវត្សរ៍មកហើយនៅកម្ពុជា កាន់តែធ្លាក់ចុះបន្ថែមទៀត។ កុមារជាច្រើនមិនទទួលបានស្តង់ដាររៀនសូត្រសមស្របតាមអាយុ រួមទាំងអក្ខរភាព និងលេខនព្វន្តកម្រិតមូលដ្ឋាន ទោះបីជាមានការវិនិយោគជាច្រើនឆ្នាំទៅលើការអប់រំថ្នាក់បឋមសិក្សា ឬ អនុវិទ្យាល័យក៏ដោយ។ អត្រាចុះឈ្មោះចូលរៀនសរុបនៅកម្រិតមធ្យមសិក្សាបឋមភូមិគឺ ៥៦,៥% សម្រាប់ក្មេងប្រុស និង ៤៥,៣% សម្រាប់ក្មេងស្រី ដោយមានអត្រាបោះបង់ការសិក្សាចំនួន ២០%។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិមានកម្រិតទាបសម្រាប់ក្មេងស្រី (២៤,៤%) និងថយចុះសម្រាប់ក្មេងប្រុស (២០,១%)។

---

10 ប្រភព ៖ អង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជា ការអង្កេតស្តីពីផលប៉ះពាល់នៃជំងឺកូវីដ ១៩ លើគ្រួសារងាយរងគ្រោះនៅកម្ពុជា ឆ្នាំ ២០២១ (ចេញផ្សាយនៅខែ ឧសភា ឆ្នាំ ២០២១)។

ជំងឺកូវីដ ១៩ បានធ្វើឱ្យ **បន្ទុកបំណុលគ្រួសារកាន់តែកើនឡើង** ជាពិសេស គ្រួសារក្រីក្រមានការលំបាកយ៉ាងខ្លាំងក្នុងការសងបំណុល។ របាយការណ៍ថ្មីមួយបានរកឃើញថា នៅអំឡុងឆ្នាំ ២០១៩-២០២០ គ្រួសារចំនួន ១,២៥លាន បានជំពាក់បំណុលដែលមានចំនួនកើនឡើង ២,៥% ពីតួលេខ ១,២២លានគ្រួសារ នៅឆ្នាំ ២០១៧ (ក្នុងចំណោមប្រជាជនសរុប ៣,៦លានគ្រួសារនៅកម្ពុជា)។ ការអង្កេតនេះបង្ហាញថា ទំហំបំណុលមធ្យមកើនចំនួន ៨៥% គឺពី ៩,៦លានរៀល ដល់ ១៧,៧លានរៀល ឬប្រហែល ២.៤០០-៤.៤០០ដុល្លារ ក្នុងមួយគ្រួសារ ។[11]

មួយរយៈនៃការឆ្លងរាលដាលជំងឺកូវីដ ១៩ បានបង្វែរ **លំហូរនៃការធ្វើចំណាកស្រុក** (ជនចំណាកស្រុកជាច្រើនត្រូវបានបង្ខំឱ្យត្រឡប់មកកម្ពុជាវិញ ជាពិសេស នៅប្រទេសថៃ ក៏ដូចជាបណ្ដាប្រទេសផ្សេងទៀត ដូចជា កូរ៉េខាងត្បូង និងម៉ាឡេស៊ី) និងបានបញ្ឈប់លំហូរនៃការធ្វើចំណាកស្រុកយ៉ាងច្រើនចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ និងប្រទេសផ្សេងទៀត។ ទោះយ៉ាងណានៅពេលបើកច្រកព្រំដែនឡើងវិញ ប្រហែលជានឹងមានការធ្វើចំណាកស្រុកច្រើនមិនធ្លាប់មានពីមុនមក ដោយសារពួកគេព្យាយាមប៉ះប៉ូវការខាតបង់ក្នុងអំឡុងវិបត្តិជំងឺកូវីដ ១៩។



11 សូមមើលអត្ថបទ ៖ ការបាត់បង់ដីធ្លី បំណុលកើនឡើង ក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចថ្មីបំផុត ៖ https://vodenglish.news/land-loss-debt-rise-recorded-in-latest-socio-economic-survey/

# មេរៀនទទួលបានពី
# យុទ្ធសាស្ត្រប្រចាំប្រទេសលើកមុន



# ទំនាក់ទំនងក្នុងភាពជាដៃគូយុទ្ធសាស្រ្ត

ធ្វើការជាមួយអង្គការដៃគូតិចជាងមុន ប៉ុន្តែធ្វើការប្រកបដោយយុទ្ធសាស្រ្តដើម្បីអភិវឌ្ឍសមត្ថភាពដៃគូអនុវត្ត។ ដោយសារតែអង្គការថ្លែនអន្តរជាតិកម្ពុជា ពង្រីកសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្ររបស់ខ្លួនកាន់តែខ្លាំងឡើង ដោយបន្ថែមលើការអនុវត្តកម្មវិធី ដូច្នេះយើងចាំបាច់ត្រូវគិតគូរពីស្ថាប័នដៃគូយុទ្ធសាស្រ្តមានសក្តានុពលផ្សេងទៀត ដូចជា ការស្វែងរកភាពជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ និង/ឬវិស័យឯកជននានា។

# ការផ្តោតអាទិភាពលើការរៀបចំកម្មវិធីប្រែក្លាយជាគម្រោងដែលមានទស្សនទានយេនឌ័រ

ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ទាំងក្នុងអង្គការថ្លែនអន្តរជាតិកម្ពុជា ( ឧ. ជាមួយបុគ្គលិក និងការរៀបចំកម្មវិធី ) ហើយនិងជំរុញការចូលរួមពីខាងក្រៅដើម្បីបង្កើនការយល់ដឹង និងបំពាក់បំប៉នអ្នកពាក់ព័ន្ធឱ្យគិតគូរ និងអនុវត្តសកម្មភាពការប្រែក្លាយជាគម្រោងដែលមានទស្សនទានយេនឌ័រ។ ការកសាងសមត្ថភាពបុគ្គលិកស្តីពីយេនឌ័រ និងបរិយាបន្នតាមរយៈការអនុវត្តពីមុនគឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ។ ហេតុដូច្នេះហើយ ទើបកម្មវិធីស្នូលនីមួយៗនៃយុទ្ធសាស្រ្តប្រចាំប្រទេសថ្មីមានដាក់បញ្ចូលគោលដៅយូរអង្វែងប្រកបដោយទស្សនទានយេនឌ័រ និងកំណត់ច្បាស់លាស់ពីជំហានឈានទៅរកការអនុវត្ត។ យើងមានក្របខ័ណ្ឌពិនិត្យតាមដានដើម្បីវាស់វែងវិសាលភាព និងពេលវេលានៃការសម្រេចបានគោលដៅទាំងនោះ។

# ការពង្រឹងការចូលរួមជាមួយតួអង្គសំខាន់ៗ

**បង្កើនគុណភាពនៃកម្មវិធីរបស់អង្គការថ្លែនអន្តរជាតិកម្ពុជាក្នុងការបំពេញការងារប្រកបដោយយុទ្ធសាស្រ្តជាងមុនជាមួយតួអង្គសំខាន់ៗ រួមមាន៖**

**ទី១** ការអនុវត្តកម្មវិធី និងកិច្ចសហការស្វែងរកមតិគាំទ្រតាមរចនាសម្ព័ន្ធរដ្ឋបាល ចាប់ពីថ្នាក់ភូមិរហូតដល់ថ្នាក់ឃុំ ស្រុក ខេត្ត និងក្រសួង ដោយត្រូវរួមបញ្ចូលការផ្តល់ព័ត៌មានមូលដ្ឋានដល់អ្នកម្ចាស់សិទ្ធិ និងអ្នកមានកាតព្វកិច្ច ក៏ដូចជាការជួយបង្កើត និងពង្រឹងសមត្ថភាពប្រព័ន្ធថ្នាក់ភូមិ។

**ទី២** នៅក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្តការរៀបចំកម្មវិធីប្រែក្លាយជាគម្រោងដែលមានទស្សនទានយេនឌ័រ អង្គការថ្លែនអន្តរជាតិកម្ពុជាគួរជំរុញការចូលរួមកាន់តែច្រើនរបស់បុរសនៅក្នុងយុទ្ធសាស្រ្តផ្លាស់ប្តូរឥរិយាបថសង្គម។

**ទី៣** សេវាសង្គមនៅតែគ្មានប្រសិទ្ធភាព ដោយសារតែលទ្ធភាពនៃការផ្តល់សេវា និងសមត្ថភាពរបស់បុគ្គលិកសង្គមកិច្ចជួរមុខនៅមានកម្រិត។ អង្គការថ្លែនអន្តរជាតិកម្ពុជា អាចដើរតួនាទីប្រកបដោយយុទ្ធសាស្រ្តនៅក្នុងការពង្រឹងសមត្ថភាពរបស់បុគ្គលិកសង្គមកិច្ចជួរមុខ ក៏ដូចជាលើកកម្ពស់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយដែលពាក់ព័ន្ធ។

**ទី៤** ការជំរុញការចូលរួមដែលមានលក្ខណៈជាប្រព័ន្ធ និងប្រកបដោយការគិតគូរកាន់តែច្រើនថែមទៀតជាមួយស្ថាប័នផ្សព្វផ្សាយព័ត៌មានជាតិ និងបណ្តាញសង្គម ដែលនឹងលើកកម្ពស់ការផ្សព្វផ្សាយសកម្មភាពនៃកិច្ចសហការស្វែងរកមតិគាំទ្រកម្មវិធី និងកេរ្តិ៍ឈ្មោះរបស់អង្គការថ្លែនអន្តរជាតិកម្ពុជា ដើម្បីនាំទៅដល់ការសម្រេចបានលទ្ធផលកាន់តែប្រសើរសម្រាប់សហគមន៍គោលដៅ។

## ការលើកស្ទួយសំឡេងរបស់យុវជន

ចំណុចសំខាន់គឺក្រុមគោលដៅរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា ជាពិសេសមនុស្សវ័យជំទង់ និងស្ត្រីវ័យក្មេង ត្រូវមានឱកាសនិយាយពីជីវិតរស់នៅ និងអាទិភាពរបស់ពួកគេ ជាជាងទុកឱ្យអង្គការភ្លែនអន្តរជាតិកម្ពុជា ជាអ្នកនិយាយជំនួសពួកគេ។ វិធីសាស្ត្រក្នុងការផ្តល់ឱកាសសម្រាប់ពួកគេ គឺអង្គការភ្លែនអន្តរជាតិកម្ពុជា ត្រូវជំរុញការចូលរួមយ៉ាងសកម្មរបស់បណ្តាញយុវជនដែលមានស្រាប់ មិនថាបណ្តាញទាំងនោះជាស្ថាប័នដែលចុះបញ្ជីផ្លូវការ ឬ មិនផ្លូវការឡើយ។

## ការទាញយកផលប្រយោជន៍ពីប្រព័ន្ធផ្សព្វផ្សាយឌីជីថលប្រកបដោយភាពច្នៃប្រឌិតជាងមុន

អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងបន្តប្រើប្រាស់វេទិកាឌីជីថលទាំងសម្រាប់គោលបំណងផ្ទៃក្នុង (កិច្ចប្រជុំ ការពិគ្រោះយោបល់ដំណើរការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ) និងការបង្កើនការចូលរួមពីខាងក្រៅ (ឧ. ការប្រើកម្មវិធីតាមប្រព័ន្ធអនឡាញសម្រាប់កិច្ចប្រជុំជាមួយក្លឹបកុមារ)។



# ការឆ្លើយតបជាយុទ្ធសាស្ត្រ
# របស់អង្គការភ្លែនអន្តរជាតិកម្ពុជា



| សំណួរយុទ្ធសាស្ត្រទាំង ៧ | ជម្រើសជាយុទ្ធសាស្ត្ររបស់អង្គការភ្លែនអន្តរជាតិកម្ពុជា |
|---|---|
| **១** ហេតុអ្វីបានជាយើងមានវត្តមាននៅទីនេះ ? ( មហិច្ឆតា ) | **សំឡេងរបស់ក្មេងស្រី៖** យើងនឹងសហការក្នុងភាពជាដៃគូយុទ្ធសាស្ត្រដើម្បីលើកកម្ពស់សិទ្ធិអំណាចក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅកម្ពុជានៅក្នុងភាពចម្រុះផ្សេងគ្នារបស់ពួកគេ - ដើម្បីលើកស្ទួយសម្លេង និងគាំទ្រពួកគេក្នុងការទទួលបានចំណេះដឹង ជំនាញ និងទំនុកចិត្តដែលពួកគេត្រូវការដើម្បីបំពេញបានសិទ្ធិ និងសម្រេចបានសក្តានុពលពេញលេញរបស់ខ្លួន។ |
| **២** តើយើងមានវត្តមាននៅទីនេះដើម្បីនរណា ? | • **ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង** និងក្រុមដែលមិនទទួលបានការយកចិត្តទុកដាក់ និងប្រឈមនឹងការរើសអើង រួមមាន **ក្រុមជនជាតិដើមភាគតិច អ្នករស់នៅក្នុងតំបន់ភូមិសាស្ត្រជួបការលំបាក ក្រុមមានអត្តសញ្ញាណគ្រួសារក្រីក្រនៅទីជនបទ និងទីប្រជុំជន ក្រុមមានពិការភាព និងក្រុមមានទំនោរនិន្នាការស្រឡាញ់ភេទដូចគ្នា។**<br>• យើងនឹងបន្តធ្វើការជាមួយក្មេងប្រុស និងបុរស ដែលពួកគេគឺជាភ្នាក់ងារផ្លាស់ប្តូរដ៏សំខាន់។ |
| **៣** តើយើងនឹងធ្វើអ្វីខ្លះជាមួយពួកគេ ? | • យើងនឹងធ្វើការជាមួយក្រុម**ក្មេងស្រីវ័យជំទង់ ( ១២-១៧ ឆ្នាំ ) និងស្ត្រីវ័យក្មេង ( ១៨-២៤ ឆ្នាំ )** ដើម្បីពង្រឹងសមត្ថភាព និងភាពធន់ដែលអាចជួយឱ្យពួកគេអភិវឌ្ឍខ្លួនជាមនុស្សពេញវ័យប្រកបដោយសក្តានុពល។<br>• ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងក្នុងនាមជា៖<br>១ ) បុគ្គល<br>២ ) អ្នកមានសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច<br>៣ ) អ្នកធ្វើសេចក្តីសម្រេចចិត្ត<br>៤ ) អ្នកមានឥទ្ធិពល។ |
| **៤** តើយើងនឹងអនុវត្តកម្មវិធីនៅកន្លែងណាខ្លះ ? | • ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ជាខេត្តអាទិភាព<br>• ខេត្តសៀមរាប ( កំពុងបិទបញ្ចប់កម្មវិធីកុមារទំនុកបម្រុងក្នុងស្រុកមួយចំនួន )<br>• ខេត្តឧត្តរមានជ័យ (អាចពង្រីកកម្មវិធីកុមារទំនុកបម្រុងនៅទីនោះ ហើយនិងបង្កើតការិយាល័យនៅខេត្តសៀមរាប )<br>• តំបន់ប្រជុំជន ( ក្រុងភ្នំពេញ ក្រុងសៀមរាប )<br>• ទីតាំងផ្សេងទៀតដែលអនុវត្តសកម្មភាពគម្រោង ឬ តម្រូវសម្រាប់សកម្មភាពឆ្លើយតបគ្រោះអាសន្ន។ |

| | |
|---|---|
| **៥ តើយើងនឹងធ្វើការជាមួយនរណា ?** | • យើងនឹងសហការជាមួយ ហើយនិងអនុវត្តសកម្មភាពកិច្ចសហការ ស្វែងរកមតិគាំទ្រជាមួយ **ស្ថាប័នរាជរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍អន្តរជាតិ។**<br>• យើងនឹងពង្រឹងសមត្ថភាព និងអនុវត្តរួមគ្នាជាមួយ **អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក** តាមរយៈភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលអាចជួយយើងសម្រេចបានទស្សនវិស័យ និងមហិច្ឆតារបស់យើង។<br>• យើងនឹងជំរុញការចូលរួមរបស់ស្ថាប័នដៃគូវិស័យឯកជនដែលមានសក្តានុពល ដូចជា សាកលវិទ្យាល័យ និងវិស័យឯកជន ជាពិសេស ដើម្បីពន្លឿននវានុវត្តន៍ឌីជីថល។<br>• យើងនឹងធ្វើការជាមួយ និងលើកកម្ពស់សិទ្ធិអំណាចរបស់ **ក្មេងស្រី ក្មេងប្រុស អ្នកមានឥទ្ធិពលជាយុវជន និងអង្គការយុវជននៅកម្ពុជា។** |
| **៦ តើអង្គការភ្លែនអន្តរជាតិកម្ពុជាត្រូវរៀបចំរចនាសម្ព័ន្ធក្នុងរូបភាពបែបណា ?** | • **ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលបានចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។**<br>• យើងនឹងបន្តធ្វើការជាមួយ **អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សហគមន៍ និងយុវជន។** ដើម្បីបង្កើនភាពស្របច្បាប់ ភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបានរបស់យើង យើងនឹងកសាងសមត្ថភាពផ្នែកបច្ចេកទេសក្នុងការផ្តល់សេវាប្រកបដោយគុណភាព និងមានបរិយាបន្នដល់ក្រុមមានឥទ្ធិពលរបស់យើង ដែលស្វែងរកមតិគាំទ្រពីរាជរដ្ឋាភិបាលនៅក្នុងការងាររៀបចំផែនការ ការបែងចែកមូលនិធិ និងការអនុវត្តសកម្មភាព ការពង្រីកវិសាលភាពដោយផ្អែកលើភស្តុតាង។<br>• វប្បធម៌នៃភាពជាអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រ ដែលត្រូវបានបង្កើតឡើងក្នុងអង្គការភ្លែនអន្តរជាតិកម្ពុជា។ |
| **៧ តើយើងនឹងផ្តល់មូលនិធិដើម្បីអនុវត្តការងាររបស់យើងដោយរបៀបណា ?** | • យើងនឹង**បែងចែកជំនួយមូលនិធិទៅតាមគម្រោងនីមួយៗ** និងបង្កើនមូលនិធិសម្រាប់កម្មវិធីកុមារទំនុកបម្រុង។<br>• យើងនឹង**ខិតខំប្រឹងប្រែងយ៉ាងសកម្ម** ដើម្បីទទួលបានជំនួយមូលនិធិប្រកបដោយគុណភាព និងរយៈពេលវែងនៅក្នុង អង្គការភ្លែនអន្តរជាតិ និងពីម្ចាស់ជំនួយខាងក្រៅ តាមរយៈភាពជាដៃគូជិតស្និទ្ធជាមួយប្រទេសរកជំនួយនៃអង្គការភ្លែនអន្តរជាតិ ( NOs )។<br>• យើងនឹង**បន្តកៀរគរមូលនិធិ**រយៈពេលវែងប្រកបដោយគុណភាពនៅក្នុងអង្គការភ្លែនអន្តរជាតិ និងពីម្ចាស់ជំនួយខាងក្រៅ ដោយសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសរកជំនួយនៃអង្គការភ្លែនអន្តរជាតិ ( NOs )។<br>• យើងនឹង**ជំរុញការចូលរួមជាយុទ្ធសាស្ត្រ**របស់ដៃគូអភិវឌ្ឍន៍សំខាន់ៗ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលមានទស្សនវិស័យដូចគ្នានៅកម្ពុជា ដើម្បីទទួលបានភាពជោគជ័យនៅក្នុងការកៀរគរធនធាន។<br>• យើងនឹងអនុវត្តឱ្យបានកាន់តែល្អប្រសើរបំផុតនៅក្នុងការចាត់ចែង គ្រប់គ្រងជំនួយមូលនិធិ ដើម្បីធានានិរន្តរភាពនៃប្រតិបត្តិការរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា។ |

# សកម្មភាពរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា

អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងអនុវត្តយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងពេលធ្វើការជាមួយក្មេងស្រីវ័យជំទង់ (១២-១៧ឆ្នាំ) និង ស្ត្រីវ័យក្មេង (១៨-២៤ឆ្នាំ) ដើម្បីពង្រឹងសមត្ថភាព និងភាពធន់ដែលអាចជួយឱ្យពួកគេអភិវឌ្ឍខ្លួនជាមនុស្សពេញវ័យប្រកបដោយសក្ដានុពល។ នេះជាការលើកឡើងជាក់ស្ដែងក្នុងយុទ្ធសាស្ត្រជាសកលរបស់អង្គការភ្លែនអន្តរជាតិដែលមានគោលបំណងជួយដល់ក្មេងស្រីអាច **រៀនសូត្រ ដឹកនាំ សម្រេចចិត្ត និងអភិវឌ្ឍ។** ការរៀបចំកម្មវិធី និងកិច្ចការស្វែងរកមតិគាំទ្ររបស់យើងភ្ជាប់នឹងកម្មវិធីផ្អែកលើភស្តុតាងដែលផ្ដល់មូលដ្ឋានសម្រាប់កិច្ចសហការស្វែងរកមតិគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## សម្លេងរបស់ក្មេងស្រី

យើងនឹងសហការក្នុងភាពជាដៃគូយុទ្ធសាស្ត្រដើម្បីលើកកម្ពស់សិទ្ធិអំណាចក្មេងស្រី ជាពិសេសក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅកម្ពុជា - នៅក្នុងភាពចម្រុះផ្សេងគ្នារបស់ពួកគេ - ដើម្បីលើកស្ទួយសម្លេង និងគាំទ្រពួកគេក្នុងការទទួលបានចំណេះដឹង ជំនាញ និងទំនុកចិត្តដែលពួកគេត្រូវការដើម្បីបំពេញបានសិទ្ធិ និងសម្រេចបានសក្ដានុពលពេញលេញរបស់ខ្លួន។




## ខាងក្រោមនេះគឺជាខ្លឹមសារលម្អិតនៃការរៀបចំកម្មវិធីរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា ជាមួយ ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ៖

- ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង...ក្នុងនាមជាបុគ្គល៖ យើងនឹងផ្តោតសំខាន់លើការអប់រំ និងការអភិវឌ្ឍជំនាញសម្រាប់ការងារទទួលបានប្រាក់ឈ្នួល និងការប្រកបរបររកស៊ីដែលផ្ដល់ប្រាក់ចំណេញដើម្បីឱ្យពួកគេចម្រើនវ័យមានជំនាញចាំបាច់សម្រាប់ការងារ និងជីវិតប្រកបដោយអត្ថន័យ។
  **កម្មវិធី និងកិច្ចសហការស្វែងរកមតិគាំទ្រ៖** ការអប់រំ (ការរក្សាអនាម័យនៅពេលមករដូវ) កិច្ចការពារកុមារប្រកបដោយទស្សនទានយេនឌ័រដែលភ្ជាប់នឹងសកម្មភាពស្វែងរកការគាំទ្រមតិនៅក្នុងការលើកទឹកចិត្តក្មេងស្រីត្រលប់ចូលរៀនវិញ និងបន្តការសិក្សា (ជាពិសេស ក្រោយវិបត្តិជំងឺកូវីដ ១៩) ហើយនិងភាពធន់ និងការស្វែងរកការគាំទ្រមតិរួមគ្នាតាមរយៈការរួមកម្លាំងគ្នា (នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលមានទស្សនវិស័យដូចគ្នា) ក្នុងការអនុវត្តគោលនយោបាយ និងច្បាប់ថ្មីស្ដីពីកិច្ចការពារកុមារ។

- **ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង...ក្នុងនាមជាអ្នកមានសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច៖** យើងនឹងធ្វើការជាមួយអ្នកពាក់ព័ន្ធទាំងអស់ដើម្បីផ្តល់ចំណេះដឹង ជំនាញ និងទំនុកចិត្តដល់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងទៅតាមតម្រូវការរបស់ពួកគេ (រួមទាំងសមត្ថភាពផ្នែកឌីជីថល និងការលើកកម្ពស់សិទ្ធិអំណាចផ្នែកហិរញ្ញវត្ថុ) ដើម្បីសម្រេចបានសក្តានុពលពេញលេញរបស់ពួកគេ។
  **កម្មវិធី និងកិច្ចសហការស្វែងរកមតិគាំទ្រ៖** ការបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនាញទន់ ឬ បំណិនជីវិត (សុខភាពផ្លូវភេទ និងសិទ្ធិរបស់មនុស្សវ័យក្មេង) សហគ្រិនភាពដែលភ្ជាប់នឹងការស្វែងរកការគាំទ្រមតិស្តីពីសុវត្ថិភាពនៅកន្លែងធ្វើការ។
- **ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង...ក្នុងនាមជាអ្នកធ្វើសេចក្តីសម្រេចចិត្ត៖** យើងនឹងគាំទ្រពួកគេក្នុងការសម្រេចចិត្តបែបវិជ្ជមានសម្រាប់ខ្លួនឯង និងនៅក្នុងគ្រួសារ តាមរយៈការដោះស្រាយបទដ្ឋានសង្គមស្មុគស្មាញ ការផ្តល់លទ្ធភាពឱ្យពួកគេក្នុងការបង្កើតជម្រើសសម្រាប់ខ្លួនឯង និងជីវិតរបស់ខ្លួន ដូចជា ការរៀបការ និងការមានផ្ទៃពោះ និងការចិញ្ចឹមកូនមានសុខភាពល្អ។
  **កម្មវិធី និងកិច្ចសហការស្វែងរកមតិគាំទ្រ៖** ការរៀបចំកម្មវិធីពហុវិស័យ (ការចិញ្ចឹមកូនបែបវិជ្ជមាន ការគាំពារនិងអភិវឌ្ឍន៍កុមារតូច អាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ) សុខភាពផ្លូវភេទ និងសិទ្ធិ ដែលភ្ជាប់នឹងសកម្មភាពស្វែងរកការគាំទ្រមតិស្តីពីការរៀបការ និងការមានផ្ទៃពោះនៅវ័យក្មេង។
- **ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង...ក្នុងនាមជាអ្នកមានឥទ្ធិពល៖** យើងនឹងធ្វើការជាមួយអ្នកពាក់ព័ន្ធទាំងអស់ដើម្បីបង្កើតបរិយាកាសអំណោយផលដែលក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងអាចធ្វើជាភ្នាក់ងារផ្លាស់ប្តូរដ៏សកម្មនៅក្នុងការសម្រេចបានសក្តានុពល និងសិទ្ធិរបស់ពួកគេ ដូចជា តាមរយៈបណ្តាញសង្គម និងពង្រីកឱកាសដែលអាចជួយឱ្យក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងទទួលបានភាពជោគជ័យក្នុងការអភិវឌ្ឍខ្លួនជាមនុស្សពេញវ័យប្រកបដោយសក្តានុពល។
  **កម្មវិធី និងកិច្ចសហការស្វែងរកមតិគាំទ្រ៖** ការលើកកម្ពស់សិទ្ធិអំណាច និងភាពជាអ្នកដឹកនាំរបស់ក្មេងស្រីដែលភ្ជាប់នឹងសកម្មភាពស្វែងរកការគាំទ្រមតិក្នុងការបង្កើនការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងកិច្ចសហការស្វែងរកមតិគាំទ្រលើការផ្លាស់ប្តូរជាវិជ្ជមាន និងប្រកបដោយនិរន្តរភាពសម្រាប់ស្ត្រីនៅកម្ពុជា។

**កម្មវិធីស្នូលទាំង ៤ របស់អង្គការភ្លែនអន្តរជាតិកម្ពុជា ផ្អែកលើអភិក្រមវដ្តជីវិតប្រកបដោយទស្សនទានយេនឌ័រដែលផ្តោតសំខាន់លើស្ត្រី ប៉ុន្តែក៏រួមបញ្ចូលបុរសនៅក្នុងកម្មវិធីផងដែរ គឺតាមរយៈអន្តរាគមន៍សម្រាប់វ័យចាប់ពីកុមារភាពដល់ជំទង់ ហើយបន្តរហូតដល់ពេញវ័យដំបូង (សម្រាប់ខ្លឹមសារលម្អិត សូមមើលឧបសម្ព័ន្ធ)។**



យុទ្ធសាស្ត្រប្រចាំប្រទេសឆ្នាំ ២០២១-២០២៦ នឹងបន្តកសាងគំរូអន្តរាគមន៍ផ្អែកលើភស្តុតាងដោយស្របទៅតាមបរិបទនៅក្នុងប្រទេសកម្ពុជាដែលយុវជនមានភាពស្វាហាប់ប្រែកបដោយថាមពល។

ទ្រឹស្តីនៃការផ្លាស់ប្តូររបស់ផែនការយុទ្ធសាស្ត្រ៖




ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងត្រៀមខ្លួនដើម្បីកំណត់អនាគតរបស់ពួកគេ

ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងមានសិទ្ធិគ្រប់គ្រងលើជីវិត និងរាងកាយរបស់ពួកគេ ហើយអាចដោះស្រាយបញ្ហាកើតឡើងទាក់ទងនឹងពួកគេ

ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងចម្រើនវ័យមានការអប់រំ និងមានចំណេះដឹងជាមួយនឹងជំនាញចាំបាច់សម្រាប់ការងារ និងជីវិត

## សម្លេងរបស់ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង

យើងនឹងសហការក្នុងភាពជាដៃគូយុទ្ធសាស្ត្រដើម្បីលើកកម្ពស់សិទ្ធិអំណាចក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅកម្ពុជា - **នៅក្នុងភាពចម្រុះផ្សេងគ្នារបស់ពួកគេ** - ដើម្បីលើកស្ទួយសម្លេង និងគាំទ្រពួកគេក្នុងការទទួលបានចំណេះដឹង ជំនាញ និងទំនុកចិត្តដែលពួកគេត្រូវការ ដើម្បី **ទទួលបានសិទ្ធិ** និងបំពេញបាន **សក្តានុពលពេញលេញរបស់ខ្លួន។**

ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង

**២,៥លាននាក់**

នៅប្រទេសកម្ពុជា ២០២១-២០២៦

# តើអង្គការភ្លែនអន្តរជាតិកម្ពុជា នឹងអនុវត្តកម្មវិធីនៅកន្លែងណាខ្លះ ?

- នៅក្នុងយុទ្ធសាស្ត្រប្រចាំប្រទេសថ្មី (២០២១-២០២៦) អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងបន្តអនុវត្តសកម្មភាពនៅក្នុង **ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី** ដែលជាខេត្តអាទិភាពខ្ពស់ ដោយសារខេត្តទាំងពីរនេះមានករណីជាច្រើននៃការរំលោភបំពានសិទ្ធិកុមារ និងសិទ្ធិក្មេងស្រី ហើយនិងចំនួនយ៉ាងច្រើននៃក្រុមដែលត្រូវបានគេមិនយកចិត្តទុកដាក់ (ជនជាតិដើមភាគតិច)។ បច្ចុប្បន្ន យើងមានគម្រោងជាច្រើន កម្មវិធីកុមារទំនុកបម្រុង និងសកម្មភាពឆ្លើយតបគ្រោះអាសន្នផ្នែកមនុស្សធម៌កំពុងអនុវត្តនៅទីនោះ។ ក្រៅពីនេះ យើងអាចនឹងពង្រីកកម្មវិធីកុមារទំនុកបម្រុង និងសកម្មភាពគម្រោងក្នុងស្រុកផ្សេងទៀតនៃតំបន់ប្រតិបត្តិកម្មវិធីខេត្តរតនគិរី។
- **នៅខេត្តសៀមរាប** អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងវាយតម្លៃលទ្ធភាពនៃការបញ្ចប់ប្រតិបត្តិការក្នុងខេត្តនេះ ដើម្បីកាត់បន្ថយស្រុកមួយចំនួនដែលអនុវត្តកម្មវិធីកុមារទំនុកបម្រុង ប៉ុន្តែនៅបន្តអនុវត្តសកម្មភាពគម្រោងដែលគាំទ្រដោយជំនួយមូលនិធិ។
- **ខេត្តឧត្តរមានជ័យ** ត្រូវបានកំណត់យកជាតំបន់មានសក្តានុពលសម្រាប់ការចាប់ផ្តើមកម្មវិធី [13] ។
- អង្គការភ្លែនអន្តរជាតិកម្ពុជា នឹងពង្រីកកម្មវិធីរបស់ខ្លួនទៅតំបន់ទីប្រជុំជន រួមមាន **ទីក្រុងភ្នំពេញ** និង**ក្រុងសៀមរាប**។




[13] ដោយសារតែកម្រិតខ្ពស់នៃការរំលោភសិទ្ធិកុមារ និងក្មេងស្រី ពិន្ទុខ្ពស់ស្តីពី MPI និង HDI និងមិនសូវមានតួអង្គពាក់ព័ន្ធ។

# ការពិនិត្យតាមដាន និងវាយតម្លៃ

យើងនឹងមានការពិនិត្យឡើងវិញ ប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និងនៅពេលបញ្ចប់យុទ្ធសាស្ត្រប្រចាំប្រទេស ដើម្បីធានាថា យុទ្ធសាស្ត្រនេះនៅតែមានភាពជាប់ទាក់ទងនឹងបរិបទប្រតិបត្តិការ និងផ្តល់ព័ត៌មានសម្រាប់ការកែសម្រួលដែលអាចកើតមានឡើង។ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងនៅពេលបញ្ចប់យុទ្ធសាស្ត្រប្រចាំប្រទេសនឹងធ្វើឡើងដោយអ្នកវាយតម្លៃពីខាងក្រៅ ហើយនឹងផ្តោតលើលទ្ធផលនៃការវិភាគការវាយតម្លៃគម្រោងដែលកំពុងអនុវត្ត និងការប្រមូលទិន្នន័យបឋម (ក្នុងករណីចាំបាច់)។ ការពិនិត្យឡើងវិញប្រចាំឆ្នាំធ្វើឡើងដោយអង្គការផ្លែនអន្តរជាតិកម្ពុជាផ្ទាល់ និងផ្តោតលើការវាយតម្លៃកម្រិតនៃការអនុវត្តគម្រោង និងការពិនិត្យដោយមានការចូលរួមលើវឌ្ឍនភាពប្រចាំឆ្នាំ (APPRs) ដែលផ្តោតលើការប្រមូលមតិត្រឡប់ និងទស្សនៈពីអ្នកទទួលផល និងអ្នកពាក់ព័ន្ធ នៅក្នុងកម្រិតជាកុមារ គ្រួសារ និងសហគមន៍ (មិនមែនកម្រិតរដ្ឋាភិបាល)។

ក្រៅពីនេះ នឹងមានការពិនិត្យឡើងវិញលើកម្មវិធីតាមវិស័យជាមួយក្រសួងពាក់ព័ន្ធ និងអង្គភាពវិមជ្ឈការរបស់ក្រសួងទាំងនោះក៏ដូចជាដៃគូអនុវត្តន៍ និងអ្នកពាក់ព័ន្ធតាមវិស័យ។ ការពិនិត្យឡើងវិញប្រចាំឆ្នាំ និងការពិនិត្យឡើងវិញលើកម្មវិធីតាមវិស័យ នឹងវាយតម្លៃលើវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបានចំណុចសំខាន់ៗ ដែលបានកំណត់ខាងលើ។ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនឹងត្រូវបានរំលេចក្នុងសំណើគម្រោងដើម្បីធានាការបន្សុីគ្នា ហើយលទ្ធផលនៃការប្រមូលទិន្នន័យក្នុងការពិនិត្យតាមដាន និងវាយតម្លៃនឹងផ្តល់មូលដ្ឋានដល់របាយការណ៍ សំណើ និងការចងក្រងឯកសារ។

ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ នឹងត្រូវបានបង្កើតឡើងសម្រាប់គោលបំណង និងលទ្ធផលនៃកម្មវិធីស្នូល។ សូចនាករ និងឧបករណ៍ក្នុងក្របខ័ណ្ឌទាំងនេះនឹងត្រូវបានប្រើប្រាស់សម្រាប់គម្រោង/ផែនការពិនិត្យតាមដាន និងវាយតម្លៃគម្រោងជាក់លាក់។ ប្រព័ន្ធពិនិត្យតាមដានពីកម្រិតលទ្ធផល នឹងត្រូវបានបង្កើតឡើង ដើម្បីដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃសម្រាប់គោលបំណងនៃកម្មវិធីនីមួយៗ ដោយសង្កត់ធ្ងន់ទៅលើការពិនិត្យតាមដានអំពីផលប៉ះពាល់នៃការអនុវត្ត។ អង្គការផ្លែនអន្តរជាតិកម្ពុជានឹងផ្តោតលើការវាស់វែងផលប៉ះពាល់នៃលទ្ធផលអនុវត្តជាក់លាក់ដែលត្រូវបានកំណត់សម្រាប់កម្មវិធីស្នូលនីមួយៗ។

# របៀបវារៈនៃការស្រាវជ្រាវ

អង្គការផ្លែនអន្តរជាតិកម្ពុជា នឹងអនុវត្តការស្រាវជ្រាវជាច្រើនធ្វើឡើងដោយស្របទៅតាមតំបន់អន្តរាគមន៍ជាយុទ្ធសាស្ត្ររបស់ខ្លួន ដែលនឹងរួមបញ្ចូលសកម្មភាពអនុវត្តទាក់ទងទៅនឹង (ប៉ុន្តែមិនត្រូវបានកំណត់ត្រឹមនោះទេ) ការរៀបការវ័យក្មេង អន្តរាគមន៍អាហារូបត្ថម្ភ ផលប៉ះពាល់នៃកម្មវិធីពហុវិស័យ ផលប៉ះពាល់នៃជំងឺកូវីដ១៩ ការអប់រំ ការប្រកបរបរចិញ្ចឹមជីវិត និងសុខុមាលភាពរបស់ក្មេងស្រីជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង។ ការស្រាវជ្រាវដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការងាររបស់អង្គការផ្លែនអន្តរជាតិកម្ពុជាក្នុងការដោះស្រាយផ្នត់គំនិតយេនឌ័រ និងឫសគល់នៃការរើសអើងផ្អែកលើយេនឌ័រ និងការស្រាវជ្រាវស្តីពីវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពបំផុតនៅក្នុងសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រជាមួយអ្នកពាក់ព័ន្ធដើម្បីគាំទ្រការកែប្រែគោលនយោបាយនៅថ្នាក់ជាតិ។ លទ្ធផលនៃការស្រាវជ្រាវនឹងផ្តល់មូលដ្ឋានដល់ការរៀបចំកម្មវិធី និងកិច្ចខិតខំប្រឹងប្រែងក្នុងសកម្មភាពស្វែងរកមតិគាំទ្ររបស់អង្គការផ្លែនអន្តរជាតិកម្ពុជា។ ប្រធានបទស្រាវជ្រាវបន្ថែមទៀតអាចនឹងលេចឡើង នៅពេលដែលយុទ្ធសាស្ត្រប្រចាំប្រទេសត្រូវបានកែសម្រួលបន្ថែមទៀត ហើយនិងដើម្បីឆ្លើយតបទៅនឹងឱកាសទទួលបានជំនួយមូលនិធិផ្សេងៗ/ថ្មីៗ។

## ឧបសម្ព័ន្ធទី ១

# កម្មវិធី និងយុទ្ធសាស្ត្រកិច្ចសហការ ស្វែងរកមតិគាំទ្រ



## កម្មវិធីទី ១៖

# ការចាប់ផ្តើមជាមួយសុខភាពល្អ (រួមមាន កម្មវិធីពហុវិស័យនៃ អាហារូបត្ថម្ភ ការគាំពារនិងអភិវឌ្ឍន៍កុមារតូច និង ទឹកស្អាតនិងអនាម័យ)

**ចំនួនអ្នកទទួលផលដែលរំពឹងទុក៖** ស្ត្រីក្នុងវ័យបន្តពូជ ឪពុកម្តាយ និងអ្នកថែទាំ (១៥-២៤ឆ្នាំ) ក្មេងស្រី និងក្មេងប្រុស អាយុក្រោម ៦ឆ្នាំ និងឪពុកម្តាយនិងអ្នកថែទាំ សរុបចំនួន ២១៦.៦៦៦នាក់។

| គោលបំណង | លទ្ធផលសំខាន់ៗ | អន្តរាគមន៍សំខាន់ៗ |
|---|---|---|
| ត្រឹមឆ្នាំ ២០២៦ ក្មេងស្រី និង ក្មេងប្រុសមានសុខភាពល្អ ទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ ឱកាសរៀនសូត្រ និងការអភិវឌ្ឍ ដំបូងដ៏ល្អប្រសើរតាមរយៈការផ្លាស់ប្តូរ ឥរិយាបថ និងការផ្លាស់ប្តូរក្នុងសង្គម ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។ | ឪពុកម្តាយ និងអ្នកថែទាំ បានកែលម្អការអនុវត្ត ក្នុងការផ្តល់អាហារូបត្ថម្ភគ្រប់គ្រាន់ដល់កុមារ ការថែទាំសុខភាពមាតានិងកុមារ ទឹកស្អាតនិងអនាម័យ និងការរៀនសូត្រដំបូង (ការផ្លាស់ប្តូរឥរិយាបថ)។ | • លើកកម្ពស់ការប្រែក្លាយជាគម្រោងដែលមានទស្សនទាន យេនឌ័រ ការផ្លាស់ប្តូរឥរិយាបថផ្អែកតាមព័ត៌មានត្រឹមត្រូវលើ ការផ្តល់របបអាហារចម្រុះដល់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យ ក្មេងដែលមានផ្ទៃពោះ និងបំបៅដោះកូន<br>• បង្កើនលទ្ធភាពទទួលបានសេវាសុខភាពមាតា ទារក កុមារ និង អាហារូបត្ថម្ភសម្រាប់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងដែលមាន ផ្ទៃពោះ និងបំបៅដោះកូន និងកុមារអាយុក្រោម ៥ឆ្នាំ |

| | | |
|---|---|---|
| | | • លើកកម្ពស់ និងគាំទ្រឳពុកម្តាយក្នុងការចិញ្ចឹមកូនដោយផ្តល់ការថែទាំបំប៉នសម្រាប់កុមារអាយុក្រោម ៥ឆ្នាំ<br>• លើកកម្ពស់ និងពង្រឹងការចូលរួមរបស់បុរសក្នុងការអភិវឌ្ឍកុមារតូច<br>• លើកកម្ពស់សហគមន៍ដឹកនាំអនាម័យទាំងស្រុង និងការបង្កើនការយល់ដឹងអំពីទឹកស្អាត និងអនាម័យ<br>• ផ្តល់នូវសេវាកម្មទឹកស្អាត និងអនាម័យគ្រប់ជ្រុងជ្រោយ សម្រាប់កុមារអាយុក្រោម ៥ឆ្នាំ នៅក្នុងភូមិដែលគ្មានការបន្ទោបង់ពាសវាលពាសកាល។ |
| | អ្នកផ្តល់សេវាក្នុងមូលដ្ឋានបានពង្រឹង និងបង្កើនសមត្ថភាព និងលើកកម្ពស់គុណភាពនៃសេវាកម្មដើម្បីសុខភាពកុមារ ស្ថានភាពអាហារូបត្ថម្ភគ្រប់គ្រាន់ដល់កុមារ ការរៀនសូត្រដំបូង ការអភិវឌ្ឍរបស់កុមារតូច និងការទទួលបានទឹកស្អាត និងអនាម័យ (ការកសាងសមត្ថភាព)។ | • គាំទ្រការបញ្ជូន លទ្ធភាពទទួលបានសេវាដើម្បីស្តារឡើងវិញនូវបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ - ធ្ងន់ធ្ងរ និងបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ - កម្រិតស្រាល<br>• ពង្រឹងសមត្ថភាពរបស់ឳពុកម្តាយបង្គោល និងអ្នកសម្របសម្រួលស្តីពីការចិញ្ចឹមកូនដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ<br>• គាំទ្រដល់មន្ទីរអភិវឌ្ឍន៍ជនបទ និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុកក្នុងការរៀបចំផែនការ និងអនុវត្តការកែលម្អសេវាទឹកស្អាត និងអនាម័យ ដោយអនុលោមតាមផែនការសកម្មភាពជាតិ<br>• កសាងសមត្ថភាពរបស់ក្រុមអ្នកប្រើប្រាស់ទឹក ជនបង្គោលភូមិ និងឃុំ។ |

| គោលបំណង | លទ្ធផលសំខាន់ៗ | អន្តរាគមន៍សំខាន់ៗ |
| --- | --- | --- |
| | អង្គការដៃគូសង្គមស៊ីវិល និងក្រុមនៅតាមសហគមន៍ (CBG) រួមទាំង ក្រុមយុវជនបានពង្រឹងសមត្ថភាព និងបង្កើនមូលដ្ឋានធនធានរបស់ខ្លួនតាមរយៈភាពជាដៃគូដើម្បីគាំទ្រអន្តរាគមន៍កម្មវិធី ការអនុវត្ត និងសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រក្នុងគោលបំណងលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភគ្រប់គ្រាន់ដល់កុមារ ការរៀនសូត្រដំបូង និងការអភិវឌ្ឍកុមារតូច និងការទទួលបានទឹកស្អាត និងអនាម័យ។ | • គាំទ្រដល់ក្រុមគ្រួសារគោលដៅដើម្បីបង្កើនភាពងាយស្រួលក្នុងការទទួលបាន និងអាចរកបានអាហារគ្រប់គ្រាន់<br>• ពង្រឹងសមត្ថភាពរបស់ក្រុមតាមសហគមន៍ និងអង្គការសង្គមស៊ីវិលជាដៃគូ លើសេវាសុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ<br>• កសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលជាដៃគូ និងក្រុមតាមសហគមន៍ក្នុងការលើកកម្ពស់ការអនុវត្តសកម្មភាពទឹកស្អាត និងអនាម័យសម្រាប់មនុស្សគ្រប់រូប<br>• គាំទ្រសង្គមស៊ីវិលមូលដ្ឋានក្នុងការស្វែងរកការគាំទ្រមតិជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនឹងតួនាទីរបស់ពួកគេនៅក្នុងការគាំទ្រដល់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច។ |
| | ស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិកែលម្អ និងពង្រឹងគោលនយោបាយ គោលការណ៍ណែនាំ ការអនុវត្ត ការពិនិត្យតាមដាន និងការសម្របសម្រួលអន្តរវិស័យ ដើម្បីលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភគ្រប់គ្រាន់ ការរៀនសូត្រដំបូង និងការអភិវឌ្ឍកុមារតូច និងការទទួលបានទឹកស្អាត និងអនាម័យ។ | • អនុវត្តសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រលើគោលនយោបាយជាតិ គោលការណ៍ណែនាំ និងការអនុវត្តដើម្បីពង្រីកវិសាលភាព និងលើកកម្ពស់គុណភាព/ការប្រើប្រាស់សេវាសុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ<br>• គាំទ្រដល់នាយកដ្ឋានអប់រំកុមារតូចក្នុងការបង្កើនសមត្ថភាពរបស់គ្រូមត្តេយ្យសិក្សាស្តីពីគរុកោសល្យដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ<br>• សហការជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងកសាងទំនាក់ទំនងជាមួយភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលដើម្បីរៀនសូត្រពីបទពិសោធន៍ និងការអនុវត្តល្អៗ<br>• គាំទ្រការអភិវឌ្ឍ និងការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំបច្ចេកទេសសំខាន់ៗ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ និងការរៀនសូត្រ និងការផ្សព្វផ្សាយតាមវិស័យ។ |

## កម្មវិធីទី ២៖

# កិច្ចការពារជំនាន់ថ្មី (រួមមាន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្រុមមានទំនោរនិន្នាការស្រលាញ់ភេទដូចគ្នា ការរៀបការវ័យក្មេង កុមារដែលត្រូវបានឪពុកម្តាយទុកចោល រួមទាំងកម្មវិធីអន្តរប្រទេស)

**ចំនួនអ្នកទទួលផលដែលរំពឹងទុក៖** កុមារ (ក្មេងស្រីយ៉ាងតិច ៥០%) ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង កុមារដែលត្រូវបានឪពុកម្តាយទុកចោល និងក្រុមមានទំនោរនិន្នាការស្រលាញ់ភេទដូចគ្នា នៅក្នុងតំបន់គោលដៅ សរុបចំនួន ៦០.០០០នាក់ ហើយនិងអង្គការបណ្តាញសង្គមស៊ីវិលចំនួន ១២០។

| គោលបំណង | លទ្ធផលសំខាន់ៗ | អន្តរាគមន៍សំខាន់ៗ |
|---|---|---|
| កុមារ ក្មេងស្រីវ័យជំទង់ និងក្មេងប្រុសវ័យជំទង់ និងយុវជនអាយុក្រោម ១៨ឆ្នាំ និង ១៨-២៤ឆ្នាំ រស់នៅគ្មានអំពើហិង្សា គ្មានការរំលោភបំពាន គ្មានការកេងប្រវ័ញ្ច និងគ្មានការមិនអើពើ ជាពិសេស ជនរងគ្រោះដោយសារអំពើហិង្សាទទួលបានការគាំទ្រប្រកបដោយគុណភាព ហើយឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និងអាយុ។ | កុមារ ក្មេងស្រីវ័យជំទង់ ក្មេងប្រុសវ័យជំទង់ និងយុវជនអាយុក្រោម ១៨ ឆ្នាំ និង ១៨-២៤ឆ្នាំ បង្កើនចំណេះដឹង ជំនាញ ទំនុកចិត្ត និងការចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការពារខ្លួនរបស់ពួកគេ។ | • កសាងសមត្ថភាព ចំណេះដឹង និងបំណិនជីវិតស្តីពីកិច្ចការពារកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ការរៀបការវ័យក្មេង<br>• លើកកម្ពស់ការសម្រេចចិត្ត និងការអនុវត្តផ្អែកតាមព័ត៌មានទទួលបានស្តីពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសម្រាប់ក្មេងស្រីវ័យជំទង់ ក្មេងប្រុសវ័យជំទង់ និងយុវជន<br>• គាំទ្រគំនិតផ្តួចផ្តើមដែលគិតគូរពីយុវជន (លក្ខណៈយុវជនមេត្រី) ស្តីពីការលើកកម្ពស់ទំនាក់ទំនងអហិង្សា ការមិនរើសអើង បទដ្ឋានសង្គមវិជ្ជមាន ទប់ស្កាត់អំពើហិង្សាលើកុមារ ការរៀបការវ័យក្មេង និងលើកកម្ពស់សមភាពយេនឌ័រ |

| គោលបំណង | លទ្ធផលសំខាន់ៗ | អន្តរាគមន៍សំខាន់ៗ |
|---|---|---|
| | | • បង្កើតយន្តការមានលក្ខណៈឌីជីថលសម្រាប់ បណ្តឹង ការរាយការណ៍ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ការរៀបការវ័យក្មេង<br>• បង្កើតសៀវភៅណែនាំការបណ្តុះបណ្តាលបែបកុមារមេត្រីតាមរយៈកម្មវិធីអនឡាញមានលក្ខណៈឌីជីថលសម្រាប់កុមារ មនុស្សវ័យជំទង់ និងយុវជន។ |
| | គ្រួសារ សមាជិកសហគមន៍ អ្នកដឹកនាំ នៅតាមមូលដ្ឋាន និងអង្គការសង្គមស៊ីវិល ទទួលស្គាល់ និងបំពេញការទទួលខុសត្រូវរបស់ខ្លួនដើម្បីធានាថា ក្មេងស្រីវ័យជំទង់ ស្ត្រីវ័យក្មេង និងកុមារ អាចទទួលបានសិទ្ធិការពារខ្លួន។ | • បង្កើត បណ្តុះបណ្តាល គាំទ្រក្រុមឪពុកម្តាយបង្គោល និងអ្នកថែទាំស្តីពីកិច្ចការពារកុមារ ការចិញ្ចឹមកូនបែបវិជ្ជមាន ផលប៉ះពាល់នៃអំពើហិង្សាលើកុមារ ការរៀបការវ័យក្មេង ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងបទដ្ឋានសង្គម បង្កផលប៉ះពាល់អវិជ្ជមានលើកុមារ<br>• គាំទ្រ ឬ ផ្តល់ការគាំទ្រផ្នែកចិត្តសង្គមក្នុងសហគមន៍ និងការបញ្ជូនទៅរកសេវាពេទ្យវិកលចរិតសម្រាប់ឪពុកម្តាយ និងអ្នកថែទាំដែលប្រឈមនឹងភាពតានតឹង ឬ ប្រព្រឹត្តអំពើហិង្សាលើកុមារ<br>• បង្កើតសារដើម្បីទំនាក់ទំនងផ្លាស់ប្តូរឥរិយាបទ ស្តីពីកិច្ចការពារកុមារ ការរៀបការវ័យក្មេង ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងបទដ្ឋានសង្គមវិជ្ជមាននៃសមភាពយេនឌ័រសម្រាប់កុមារ ក្មេងស្រីវ័យជំទង់ ក្មេងប្រុសវ័យជំទង់ យុវជន |

| | | |
|---|---|---|
| | | • ជំរុញឱ្យឪពុកម្តាយ អ្នកថែទាំ និងក្រុមសហគមន៍គាំទ្រយុវជនក្នុងការទទួលបានសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ<br>• សម្របសម្រួលការឆ្លុះបញ្ចាំង និងកិច្ចសន្ទនាក្នុងសហគមន៍ដើម្បីកាត់បន្ថយការទទួលយកអំពើហិង្សា ការរៀបការវ័យក្មេង ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ |
| | ការបង្កើនលទ្ធភាពក្នុងការទទួលបានសេវាកិច្ចការពារកុមារដែលសមស្របតាមអាយុសម្រាប់ កុមារ ក្មេងស្រីវ័យជំទង់ ក្មេងប្រុសវ័យជំទង់ និងយុវជន ក្រុមមានទំនោរនិន្នាការស្រលាញ់ភេទដូចគ្នា និងកុមារមិនទទួលបានការយកចិត្តទុកដាក់ដែលធ្លាប់ទទួលរងផលប៉ះពាល់នៃ ( និង/ឬប្រឈមនឹង ) អំពើហិង្សា។ | • បង្កើតក្រុមការងារសង្គមថ្នាក់ឃុំ និងបណ្តុះបណ្តាលពួកគេស្តីពីការងារសង្គម ការពិគ្រោះយោបល់ ការគ្រប់គ្រងករណី និងប្រព័ន្ធបញ្ជូននៅក្នុងឃុំគោលដៅទាំងអស់របស់អង្គការផ្លែនអន្តរជាតិកម្ពុជា<br>• បង្កើត និងពង្រឹងសុខភាពបន្តពូជ និងសិទ្ធិ និងផ្តល់នូវសេវាសុខភាពសាធារណៈមានលក្ខណៈយុវជនមេត្រីដែលបង្កើនលទ្ធភាពទទួលបាន/ការប្រើប្រាស់សេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជដោយមនុស្សវ័យជំទង់ និងយុវជន<br>• ធានាបាននូវការផ្តល់ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងផ្នែកចិត្តសង្គម និងការបញ្ជូនទៅរកសេវាពេទ្យវិកលចរិតសម្រាប់កុមារដែលប្រឈមនឹងអំពើហិង្សា<br>• ជំរុញឱ្យមានសេវាសង្គ្រោះបន្ទាន់តាមប្រព័ន្ធអនឡាញសម្រាប់ការការពារកុមារ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ការពិគ្រោះយោបល់ និងការបញ្ជូនកុមារ ក្មេងស្រីវ័យជំទង់ យុវជន និងក្រុមមានទំនោរនិន្នាការស្រលាញ់ភេទដូចគ្នាដែលប្រឈមនឹងអំពើហិង្សាគ្រប់ទម្រង់ |

| គោលបំណង | លទ្ធផលសំខាន់។ | អន្តរាគមន៍សំខាន់។ |
|---|---|---|
| | | • ពង្រីក និងប្រើប្រាស់ Primero ជាឧបករណ៍គ្រប់គ្រងករណីក្នុងតំបន់គោលដៅរបស់អង្គការភ្លែនអន្តរជាតិកម្ពុជា និងកំណត់ច្បាស់ពីស្តង់ដារនីតិវិធីសម្រាប់ការបញ្ជូន និងការជួយ<br>• លើកកម្ពស់សមត្ថភាពរបស់ជនបង្គោលស្រុកដែលចូលរួមក្នុងការងារផ្តល់សេវាសង្គម គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារនូវគ្រប់ទម្រង់ ការរៀបការវ័យក្មេង និងបញ្ហាដែលពាក់ព័ន្ធនឹងកុមារដែលត្រូវបានឪពុកម្តាយទុកចោល<br>• គាំទ្រការផ្លាស់ប្តូរក្នុងវិស័យឯកជន/ជំនួញ ដើម្បីអ្នកធ្វើអាជីវកម្មដាក់បញ្ចូលទស្សនទាននៃកិច្ចការពារកុមារក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ ជាពិសេស ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ |
| | រាជរដ្ឋាភិបាលកម្ពុជាកែលម្អក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ និងយន្តការពង្រឹងការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងការការពារកុមារ ស្ត្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ការរៀបការវ័យក្មេង ដោយរួមបញ្ចូលប្រព័ន្ធពិនិត្យតាមដានទៅលើអំពើហិង្សាលើកុមារ មនុស្សវ័យជំទង់ និងយុវជន។ | • អនុវត្តសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើត កែលម្អ និងពង្រឹងការអនុវត្តច្បាប់ (ជាពិសេសច្បាប់ស្តីពីកិច្ចការពារកុមារ នីតិវិធីប្រតិបត្តិស្តង់ដារ=ច្បាប់ស្តីពីកិច្ចការពារកុមារ ផែនការយុទ្ធសាស្ត្រជាតិ-ក្រុមការងារផ្តល់សេវាសង្គម)<br>• គាំទ្រការអនុវត្ត និងពិនិត្យតាមដានគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ |

- អនុវត្តសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រជាមួយរាជរដ្ឋាភិបាលថ្នាក់ជាតិ/ថ្នាក់មូលដ្ឋានក្នុងការរៀបចំកញ្ចប់ថវិកា និងអនុវត្តផែនការសកម្មភាពថ្នាក់ខេត្តសម្រាប់ប្រព័ន្ធកិច្ចការពារកុមារ
- លើកកម្ពស់ការអនុវត្តគោលនយោបាយស្តីពីកិច្ចការពារកុមារក្នុងសាលារៀន
- ប្រព័ន្ធទទួលស្គាល់គុណភាពអប់រំទ្វេភាគី ៖ ប្រទេសថៃ និងកម្ពុជាសម្រាប់ "កុមារចំណាកស្រុក"
- ស្រាវជ្រាវ និងចងក្រងឯកសារស្តីពីកិច្ចការពារកុមារ និងប្រព័ន្ធគ្រប់គ្រងករណី និងការអនុវត្តវិជ្ជមានក្នុងសង្គមដើម្បីការពារកុមារពីអំពើហិង្សា ការរៀបការវ័យក្មេង និងលើកកម្ពស់សមភាពយេនឌ័រ។

## កម្មវិធីទី ៣៖

# រៀនមួយជីវិត (រួមមាន ការអប់រំប្រកបដោយគុណភាព និងមានបរិយាបន្ន ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សុខភាពបន្តពូជ និងសិទ្ធិរបស់មនុស្សវ័យជំទង់)

**ចំនួនអ្នកទទួលផលដែលរំពឹងទុក៖** សរុបចំនួន ១១២.០០០នាក់ រួមមាន ក្មេងស្រី និងក្មេងប្រុស អាយុ ៦-១៤ឆ្នាំ ក្មេងស្រី/ក្មេងប្រុសវ័យជំទង់អាយុ ១៥-២៤ឆ្នាំ ឪពុកម្តាយ និងអ្នកថែទាំ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់/ខេត្ត មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ ក្រុមទ្រទ្រង់សុខភាពភូមិ បុគ្គលិកផ្តល់សេវាសុខភាពសាធារណៈ ក្រុមមនុស្សវ័យជំទង់ និងយុវជនក្នុងសហគមន៍ និយោជក/ម្ចាស់សហគ្រាស។

| គោលបំណង | លទ្ធផលសំខាន់ៗ | អន្តរាគមន៍សំខាន់ៗ |
| --- | --- | --- |
| ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងមានលទ្ធភាពពេញលេញក្នុងការទទួលបានការអប់រំ និងការអភិវឌ្ឍជំនាញប្រកបដោយគុណភាព ដែលជំរុញ និងគាំទ្រដល់ការសិក្សាពេញមួយជីវិត និងមានការងារសមរម្យ។ | ការកើនឡើងនៃចំនួន កុមារ មនុស្សវ័យជំទង់ និងយុវជនដែលមិនទទួលបានការយកចិត្តទុកដាក់ ជាពិសេស ក្មេងស្រី និងកុមារ មនុស្សវ័យជំទង់ និងយុវជនមានពិការភាព ដែលបានបញ្ចប់កម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ | • ផ្តល់មធ្យោបាយធ្វើដំណើរ អាហារូបករណ៍ សម្ភារសិក្សា និងបង្កើតថ្នាក់បំប៉ន សាលារៀននៅតាមសហគមន៍ វគ្គសិក្សារៀនដោយខ្លួនឯងតាមប្រព័ន្ធអនឡាញ ក្លឹបសិក្សាដឹកនាំដោយយុវជន ដើម្បីបង្កើនការចុះឈ្មោះចូលរៀន និងការនៅបន្តការសិក្សា<br>• បង្កើតជ្រុងអំណាន/ក្រុមអំណាន បណ្ណាល័យ បណ្ណាល័យឌីជីថល ការបង្កើតប្រាក់ចំណូលក្នុងគ្រួសារ ការផ្តល់អាហារតាមសាលារៀន និងសួនសិក្សាក្នុងសាលារៀនដើម្បីបង្កើនវត្តមានសិស្ស<br>• សង់អគារសិក្សាថ្មី (សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា) និងបរិក្ខារទឹកស្អាត និងអនាម័យក្នុងសាលារៀននៅក្នុងតំបន់ដាច់ស្រយាលនៃខេត្តស្ទឹងត្រែង និងរតនគិរី |

| | | |
|---|---|---|
| | | • គាំទ្រការបំពេញមុខងាររបស់ ក្រុមប្រឹក្សាសិស្ស គណៈកម្មាធិការគ្រប់គ្រងសាលា ការជំរុញការចូលរួមរបស់គ្រួសារ និងសហគមន៍ និងយន្តការដែលឆ្លើយតបនឹងតម្រូវការយេនឌ័រក្នុងសាលារៀនដើម្បីដោះស្រាយឧបសគ្គរាំងការអប់រំរបស់ក្មេងស្រីវ័យជំទង់<br>• កសាងសមត្ថភាពរបស់អ្នកមានកាតព្វកិច្ចស្ដីពីវិធីសាស្រ្តបង្រៀនដែលផ្តោតការយកចិត្តទុកដាក់លើអ្នកសិក្សា មានបរិយាបន្ន មានការសហការ ការអប់រំពហុភាសា និងឆ្លើយតបនឹងតម្រូវការយេនឌ័រនៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ<br>• លើកកម្ពស់ការអនុវត្ត និងការសម្រេចចិត្តបែបវិជ្ជមានផ្អែកតាមព័ត៌មានទទួលបាន និងបង្កើតបរិយាកាសអំណោយផលស្តីពីសុខភាព សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងអាហារូបត្ថម្ភ អនាម័យ និងទឹកស្អាតសម្រាប់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង។ |
| | កុមារ មនុស្សវ័យជំទង់ និងយុវជនក្រៅសាលា ជាពិសេស ក្មេងស្រី និងស្ត្រីវ័យក្មេង បញ្ចប់ការអប់រំផ្លូវការនៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ។ | • បង្កើនការចុះឈ្មោះចូលរៀន/ការចូលរៀនឡើងវិញតាមរយៈយុទ្ធនាការ/ការលើកកម្ពស់ការយល់ដឹង ការចិញ្ចឹមជីវិត និងការគាំទ្រសំណាញ់សុវត្ថិភាពសង្គម (រួមទាំង ឧបត្ថម្ភសាច់ប្រាក់ (CVA)) ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះបំផុត ដែលមានកុមារដល់អាយុចូលរៀនថ្នាក់បឋមសិក្សា និងកុមារសិក្សាថ្នាក់អនុវិទ្យាល័យ និងផ្តល់អាហារូបករណ៍ទៅក្រុមគោលដៅទាំងនោះ<br>• គាំទ្រថ្នាក់ចូលរៀនឡើងវិញ ថ្នាក់សមមូលអប់រំកម្រិតមូលដ្ឋាន ការអប់រំពហុភាសា និងថ្នាក់ពន្លឿនការអប់រំសម្រាប់កុមារបោះបង់ការសិក្សាដែលមានអាយុច្រើន និងកុមារជនជាតិដើមភាគតិច |

| គោលបំណង | លទ្ធផលសំខាន់ៗ | អន្តរាគមន៍សំខាន់ៗ |
|---|---|---|
| | | • កសាងសមត្ថភាពបុគ្គលិកមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា និងគ្រូបង្រៀន ស្តីពីវិធីសាស្រ្តបង្រៀនដែលផ្តោតការយកចិត្តទុកដាក់លើអ្នកសិក្សា មានបរិយាបន្ន មានការសហការ ការអប់រំពហុភាសា និងឆ្លើយតបនឹងតម្រូវការយេនឌ័រ។ |
| | យុវជនក្រៅសាលាដែលជួបការលំបាក(១៥-២៤ឆ្នាំ) ជាពិសេស យុវតី ដែលមិនអាចចុះឈ្មោះចូលរៀនឡើងវិញ ទទួលបានការអប់រំចំណេះទូទៅ ស្វែងរកការអភិវឌ្ឍជំនាញពាក់ព័ន្ធ និងឱកាសការងារសមរម្យទៅតាមជម្រើសរបស់ខ្លួន មិនថាការងារទទួលបានប្រាក់ឈ្នួល ឬ ការប្រកបរបររកស៊ីដែលផ្តល់ប្រាក់ចំណេញនោះទេ។ | • ជំរុញការចូលរួមរបស់យុវជនជួបការលំបាក ជាពិសេស អ្នកដែលមិនមានការអប់រំ ការងារ ឬ ការបណ្តុះបណ្តាល និងស្រ្តី និងបុរសដែលមិនមានការងារធ្វើ ឬ ខ្វះជំនាញ នៅទីជនបទ និងទីប្រជុំជនក្នុងការទទួលបានឱកាសអភិវឌ្ឍជំនាញពាក់ព័ន្ធ និងមានការងារធ្វើ<br>• គាំទ្របុរស និងស្រ្តីវ័យក្មេង ឪពុកម្តាយ/អ្នកថែទាំ អ្នកផ្តល់សេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងស្ថាប័នរដ្ឋាភិបាល សហគ្រិន/និយោជក ដើម្បីផ្តល់ឱកាសដល់យុវជនក្នុងការបន្តការសិក្សាជំនាញដែលពាក់ព័ន្ធ ឬ មានការងារធ្វើ<br>• កសាងសមត្ថភាពមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា និងអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញ ដើម្បីផ្តល់ការបណ្តុះបណ្តាលមានលក្ខណៈយុវជនមេត្រី និងឆ្លើយតបនឹងតម្រូវការយេនឌ័រដល់យុវជនជួបការលំបាក ជាពិសេស ស្រ្តីវ័យក្មេង<br>• គាំទ្រសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងអាហារូបត្ថម្ភ សម្រាប់សិក្ខាកាម និងកុមារកំពុងសិក្សាក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល។ |

| | | |
|---|---|---|
| | អ្នកតាក់តែងគោលនយោបាយក្នុងស្ថាប័នរដ្ឋាភិបាល អនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយសមស្រប គ្រប់គ្រាន់ ដើម្បីផ្តល់ការអប់រំ ការអភិវឌ្ឍជំនាញ និងការងារប្រកបដោយគុណភាពខ្ពស់ ដែលមានលក្ខណៈកុមារ និងយុវជនមេត្រី ដោយឆ្លើយតបនឹងតម្រូវការយេនឌ័រ។ | • ជំរុញការចូលរួមរបស់តំណាងកុមារ និងយុវជនជួបការលំបាក រួមទាំង ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ក្នុងកិច្ចសន្ទនាស្តីពីការអប់រំ ជាមួយអ្នកតាក់តែងគោលនយោបាយ/អ្នកផ្តល់សេវាពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>• អនុវត្តសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រដើម្បីកែលម្អគោលនយោបាយ គោលការណ៍ណែនាំ និងសម្ភារ/ឯកសារអប់រំតាមរយៈការអប់រំ ការអភិវឌ្ឍជំនាញ និងការងារដែលមានលក្ខណៈកុមារ និងយុវជនមេត្រីដែលផ្អែកលើភស្តុតាង និងឆ្លើយតបនឹងតម្រូវការយេនឌ័រ<br>• សហការដើម្បីស្វែងរកមតិគាំទ្រលើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការអនុវត្តគោលនយោបាយ។ |

## កម្មវិធីទី ៤៖

# ភាពដឹកនាំរបស់ក្មេងស្រី (រួមមាន ការលើកកម្ពស់ភាពអង់អាច និងភាពជាអ្នកដឹកនាំ ភាពជាពលរដ្ឋសកម្ម និងការចូលរួមក្នុងនាមជាពលរដ្ឋ)

**ចំនួនអ្នកទទួលផលដែលរំពឹងទុក៖** ក្មេងស្រីវ័យជំទង់ (១២-១៧ឆ្នាំ) និងស្ត្រីវ័យក្មេង (១៨-២៤ឆ្នាំ) នៅទីជនបទ និងទីប្រជុំជន សរុបចំនួន ៨៩.៤៨៨នាក់។

| គោលបំណង | លទ្ធផលសំខាន់ៗ | អន្តរាគមន៍សំខាន់ៗ |
|---|---|---|
| ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងដើរតួនាទីជាភ្នាក់ងារផ្លាស់ប្តូរដ៏សកម្មនៅក្នុងការជម្នះឧបសគ្គដើម្បីសម្រេចបានសក្តានុពលពេញលេញ និងសិទ្ធិរបស់ពួកគេ។ | ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង មានចំណេះដឹងគ្រប់គ្រាន់ និងជាភ្នាក់ងាររឹងមាំក្នុងការដឹកនាំសកម្មភាពរួមដើម្បីលើកកម្ពស់សមភាពយេនឌ័រ។ | • កសាង សមត្ថភាព ភាពជាអ្នកដឹកនាំ និងជំនាញចាំបាច់ផ្សេងទៀត ដើម្បីឱ្យក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងសម្រេចបានសក្តានុពលពេញលេញរបស់ខ្លួន<br>• សម្របសម្រួលក្នុងការបង្កើតបណ្តាញនៅវេទិកាថ្នាក់ជាតិ/ថ្នាក់តំបន់ ដើម្បីជំរុញឱ្យមានរបៀបវារៈ និងសកម្មភាពរួម<br>• គាំទ្រគំនិតផ្តួចផ្តើមដែលពាក់ព័ន្ធនឹងយុទ្ធនាការ ១៦ថ្ងៃ និងយុទ្ធនាការក្មេងស្រីទទួលបានឱកាសស្មើគ្នា<br>• ធ្វើការជាមួយអ្នកណែនាំ និងបុគ្គលគំរូដែលជាមនុស្សពេញវ័យ<br>• ជួយដល់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ក្នុងការចូលរួមការពិនិត្យតាមដានការអនុវត្តរបស់គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី/ក្មេងស្រី គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលនយោបាយស្តីពីសមភាពយេនឌ័រ |

| | | |
|---|---|---|
| | | • បង្កើតសភាយុវជនដែលតំណាងឱ្យផលប្រយោជន៍ពិតប្រាកដរបស់យុវជន<br>• បង្កើតបរិយាកាស/វេទិកា/យន្តការមានសុវត្ថិភាពដែលសម្របសម្រួលក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងក្នុងការទទួលបានឱកាសរៀនសូត្រ និងការធ្វើការជាមួយគ្នា<br>• គិតគូរលើការផ្តល់ជំនួយមូលនិធិដែលមានភាពបត់បែន ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមរបស់ក្រុមមនុស្សវ័យក្មេង ឬ អង្គការយុវជន<br>• ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់អង្គការ/ក្រុមយុវជន ជាពិសេសរបៀបប្រើប្រាស់បណ្តាញសង្គមដើម្បីលើកឡើងពីបញ្ហារបស់ពួកគេ។ |
| | គ្រួសារ/អ្នកថែទាំ និងសហគមន៍គាំទ្រ និងលើកទឹកចិត្តឱ្យក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង ចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្តនៅក្រៅគ្រួសារ។ | • ជំរុញការចូលរួមរបស់គ្រួសារ អ្នកថែទាំ និងសហគមន៍ ដើម្បីគាំទ្រដល់យុវជន ជាពិសេស ស្ត្រីវ័យក្មេង ក្នុងការងារផ្លាស់ប្តូរសង្គមរបស់ពួកគេ<br>• រៀបចំកិច្ចសន្ទនាអន្តរជំនាន់ជាមួយឪពុកម្តាយដែលមានឥទ្ធិពលក្នុងជីវិតរបស់យុវជន៖ ពិភាក្សាពីការលើកកម្ពស់សិទ្ធិអំណាចរបស់ស្ត្រី (កម្រិតគ្រួសារ សហគមន៍ ស្ថាប័ន)<br>• បញ្ជ្រាបទស្សនទាននៃសមភាពយេនឌ័រក្នុងការបណ្តុះបណ្តាលឪពុកម្តាយ/អ្នកថែទាំ<br>• សម្របសម្រួលភាពជាដៃគូរវាងយុវជន ជាពិសេសស្ត្រីវ័យក្មេង និងស្ថាប័នផ្សព្វផ្សាយព័ត៌មានដើម្បីបង្កើតខ្លឹមសារដែលកាន់តែពាក់ព័ន្ធសម្រាប់ និងជាមួយយុវជន |

| គោលបំណង | លទ្ធផលសំខាន់ៗ | អន្តរាគមន៍សំខាន់ៗ |
| --- | --- | --- |
| | | • សហការជាមួយស្ថាប័នផ្សព្វផ្សាយព័ត៌មានដើម្បីលើកបង្ហាញអំពីភាពជោគជ័យ និងសមិទ្ធផលវិជ្ជមានរបស់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង<br>• លើកកម្ពស់ទស្សនទាននៃសមភាពយេនឌ័រក្នុងស្ថាប័នផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានតាមរយៈវគ្គបណ្តុះបណ្តាល និង/ឬ ការចូលរួមក្នុងព្រឹត្តិការណ៍ ដូចជា ក្មេងស្រីកាន់តួនាទីជំនួស<br>• បណ្តុះបណ្តាល និងគាំទ្រដល់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងក្នុងការប្រើប្រាស់វេទិកាបណ្តាញសង្គមដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួនប្រកបដោយសុវត្ថិភាព និងសន្តិសុខ<br>• គាំទ្រយុទ្ធនាការបង្កើនការយល់ដឹងដែលដឹកនាំដោយក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងស្តីពីភាពជាតំណាងស្មើភាព សេរីភាព និងសិទ្ធិអំណាច<br>• ចងក្រងឯកសារស្តីពីភាពជោគជ័យរបស់ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅក្នុងសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រដើម្បីចែករំលែកក្នុងវេទិកាថ្នាក់ជាតិ និងថ្នាក់តំបន់។ |
| | អ្នកតាក់តែងគោលនយោបាយក្នុងស្ថាប័នរដ្ឋាភិបាលចាប់ពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន បញ្ចូលការចូលរួមរបស់យុវជននៅក្នុងដំណើរការពិគ្រោះយោបល់ ការរៀបចំផែនការ ការរៀបចំថវិកា និង/ឬ ការធ្វើសេចក្តីសម្រេច។ | • គាំទ្រអង្គការ/ក្រុមយុវជនឱ្យដាក់បញ្ចូលបញ្ហារបស់យុវជនក្នុងរបៀបវារៈនយោបាយ តាមរយៈកិច្ចសន្ទនាស្តីពីគោលនយោបាយការងារស្វែងរកការគាំទ្រមតិ យន្តការគណនេយ្យភាពសង្គម និងសាធារណៈ<br>• អនុវត្តសកម្មភាពកិច្ចសហការស្វែងរកមតិគាំទ្រ និងគាំទ្រដល់អាជ្ញាធរមូលដ្ឋាន/ថ្នាក់ជាតិក្នុងការបង្កើត ពង្រឹង និងផ្តល់ឱកាសដល់ការចូលរួមប្រកបដោយអត្ថន័យរបស់យុវជននៅក្នុងស្ថាប័ន<br>• កសាងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានស្តីពីការចូលរួមរបស់យុវជន និងសមភាពយេនឌ័រ<br>• គាំទ្រការអនុម័ត ការអនុវត្ត និងការពិនិត្យតាមដានលើគោលនយោបាយដើម្បីលើកកម្ពស់សិទ្ធិរបស់ក្មេងស្រី និងសមភាពយេនឌ័រ។ |



# ឧបសម្ព័ន្ធទី ២

# គោលបំណងរបស់ស្ថាប័ន

| គោលបំណង | លទ្ធផល | សកម្មភាព |
| --- | --- | --- |
| **គោលបំណងទី ១៖** ពង្រឹងគុណតម្លៃរបស់យើងដោយផ្អែកតាម វប្បធម៌ភាពចម្រុះផ្សេងគ្នា ការអនុវត្តភាពជាអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រ និងមានបរិយាកាសល្អនៅកន្លែងធ្វើការ។ | **លទ្ធផល ១.១៖** ការដឹកនាំផ្អែកតាមគុណតម្លៃ គាំទ្រដោយគោលការណ៍ភាពជាអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រ។ | • **ឆ្នាំសារពើពន្ធ ២០២២៖** កំណត់រកអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រឆ្នើម ដើម្បីជំរុញការរៀបចំសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រ និងគោលការណ៍ពាក់ព័ន្ធដែលបន្ស៊ីគ្នានឹងការងារទាក់ទងនឹងអំណាចឯកសិទ្ធិ និងភាពលម្អៀង និងក្រុមប្រឹក្សាប្រឆាំងការប្រកាន់ពូជសាសន៍ និងការរើសអើង។<br>• **ឆ្នាំសារពើពន្ធ ២០២២-២០២៦៖** វាយតម្លៃភាពខ្វះចន្លោះនៃជំនាញដឹកនាំក្នុងចំណោមអ្នកគ្រប់គ្រង និងអ្នកដឹកនាំទាំងអស់ និងផ្តល់ការបណ្តុះបណ្តាលដោយផ្អែកតាមសមត្ថភាពនៃភាពជាអ្នកដឹកនាំ។ |

| គោលបំណង | លទ្ធផល | សកម្មភាព |
|---|---|---|
| | **លទ្ធផល ១.២៖** ឧបករណ៍បង្កើនការដឹកនាំ និងមគ្គុទេសក៍សម្រាប់កិច្ចសន្ទនាប្រកបដោយភាពអង់អាច។ | • **ឆ្នាំសារពើពន្ធ ២០២២ ៖** ដាក់បញ្ចូលគោលការណ៍ភាពជាអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រ/ការប្រឆាំងការប្រកាន់ពូជសាសន៍ និងការរើសអើង/អំណាច និងភាពលម្អៀងសម្រាប់បណ្តុះបណ្តាលអ្នកដឹកនាំ/អ្នកគ្រប់គ្រងទាំងអស់ និងផ្តល់ការបណ្តុះបណ្តាលបន្តដល់បុគ្គលិកគ្រប់រូប។<br>• **ឆ្នាំសារពើពន្ធ ២០២២-២០២៦ ៖** បណ្តុះបណ្តាលបុគ្គលិកគ្រប់រូប (តាមទីតាំង) ស្តីពីគោលការណ៍នៃភាពជាអ្នកដឹកនាំដែលមានទស្សនទានយេនឌ័រ និងរបៀបអនុវត្តការប្រែក្លាយជាគម្រោងដែលមានទស្សនាទានយេនឌ័រ និងមានបរិយាបន្ន ដោយផ្អែកលើអនុសាសន៍ពីស្វ័យវាយតម្លៃស្តីពីសមភាព និងបរិយាបន្ននៅកន្លែងធ្វើការ។ |
| **គោលបំណងទី ២៖** ធ្វើឱ្យកាន់តែប្រសើរឡើងនូវការអនុវត្តការងាររបស់អង្គការ និងការអនុវត្តការងាររបស់បុគ្គលិក ដោយផ្តោតសំខាន់លើវេចនាសម្ព័ន្ធ និងជំនាញ ដើម្បីទទួលបានធនធានមនុស្សគ្រប់គ្រាន់ និងមានគុណភាពតាមរយៈការរៀបចំផែនការធនធានមនុស្សដើម្បីជ្រើសរើស កសាងសមត្ថភាព និងរក្សាធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ ដែលអាចជំរុញការអនុវត្តយុទ្ធសាស្ត្រប្រចាំប្រទេសថ្មីនៅក្នុងការផ្លាស់ប្តូរជីវិតរស់នៅរបស់ក្មេងស្រីរាប់លាននាក់។ | **លទ្ធផល ២.១៖** ការអភិវឌ្ឍអង្គការ។ | • **ឆ្នាំសារពើពន្ធ ២០២២៖** អនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ (ជំនាញគ្រប់គ្រងការផ្លាស់ប្តូរ) តាមរយៈការបង្កើនជំនាញដើម្បីពង្រឹងរបៀបគ្រប់គ្រងការផ្លាស់ប្តូរ និងការជំរុញការចូលរួមរបស់ក្រុមតាមបែបប្រតិសកម្ម និងជាវិជ្ជមាន។<br>• **ឆ្នាំសារពើពន្ធ ២០២២-២០២៦៖** បង្កើត និងអនុវត្តកម្មវិធីរៀនសូត្រ និងអភិវឌ្ឍន៍ជាប្រព័ន្ធសម្រាប់បុគ្គលិកគ្រប់រូប។ |

| | | |
|---|---|---|
| | **លទ្ធផល ២.២៖** យុទ្ធសាស្ត្រផ្ដល់រង្វាន់លើកទឹកចិត្តត្រូវបានកំណត់ច្បាស់លាស់ និងអនុវត្តយ៉ាងត្រឹមត្រូវ។ | **សារពើពន្ធ ២០២២-២០២៦៖**<br>• ការចងក្រងប្រវត្តិការងារ ការធ្វើចំណាត់ថ្នាក់ការងារ និងការវាយតម្លៃការងារ<br>• ការរាយការណ៍ពីគម្លាតប្រាក់ឈ្នួលផ្អែកតាមយេនឌ័រ<br>• ការកំណត់កាំប្រាក់បៀវត្សរ៍ប្រចាំឆ្នាំ និងការពិនិត្យឡើងវិញលើកាំប្រាក់បៀវត្សរ៍ និងការដំឡើងប្រាក់ខែទៅតាមការប្រែប្រួលនៃថ្លៃទ្រទ្រង់ការរស់នៅ ( COLA )<br>• ការយកចិត្តទុកដាក់លើនិយោជិត ការផ្ដល់នូវសេវាធានារ៉ាប់រង និងការផ្ដួចផ្ដើមកម្មវិធីជួយដល់និយោជិត<br>• ការប្រឹក្សា៖ បញ្ហាទាក់ទងនឹងអន្តោប្រវេសន៍ និងពន្ធបុគ្គលិក និងការផ្ដល់ទីកន្លែងអនុវត្តការងារសម្រាប់បុគ្គលិកមកពីបណ្ដាប្រទេសផ្សេងទៀតនៃអង្គការភ្លែនអន្តរជាតិ ( Hosting Agreement)។ |
| | **លទ្ធផល ២.៣៖** យុទ្ធសាស្ត្រគ្រប់គ្រងទេពកោសល្យត្រូវបានកំណត់ច្បាស់លាស់ និងអនុវត្តយ៉ាងត្រឹមត្រូវ។ | • **ឆ្នាំសារពើពន្ធ ២០២២៖** កំណត់បរិបទ និងអនុវត្តយុទ្ធសាស្ត្រ និងឧបករណ៍គ្រប់គ្រងទេពកោសល្យ។<br>• **ឆ្នាំសារពើពន្ធ ២០២២-២០២៦៖** ធានាថា ការរៀបចំផែនការស្នងតំណែង និងដំណើរការគ្រប់គ្រងទេពកោសល្យត្រូវបានបញ្ចូលទៅក្នុងការអនុវត្តទូទាំងប្រទេសដោយមានការពិនិត្យឡើងវិញជាប្រចាំ។<br>• **ឆ្នាំសារពើពន្ធ ២០២២-២០២៦៖** បង្កើត និងអនុវត្តកម្មវិធីរៀនសូត្រ និងអភិវឌ្ឍន៍ជាប្រព័ន្ធ។ |

| គោលបំណង | លទ្ធផល | សកម្មភាព |
|---|---|---|
| **គោលបំណងទី ៣៖** ពង្រឹងប្រសិទ្ធផល ប្រសិទ្ធភាព គណនេយ្យភាពប្រតិបត្តិការ និងផលប៉ះពាល់កម្មវិធីតាមរយៈការបង្កើនការប្រើប្រាស់ និងសមត្ថភាពផ្នែកឌីជីថល។ | **លទ្ធផល ៣.១៖** ប្រព័ន្ធប្រតិបត្តិការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ | • **ឆ្នាំសារពើពន្ធ ២០២២-២០២៣ ៖** អនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងការត្រួតពិនិត្យ វាយតម្លៃ ស្រាវជ្រាវ និងរៀនសូត្រថ្មីដោយស្របទៅតាមក្របខ័ណ្ឌពេលវេលាដែលបានកំណត់ ដើម្បីធានានូវដំណើរការជាប្រព័ន្ធត្រូវបានបញ្ចូលទៅក្នុងរបៀបធ្វើការ។<br>• **ឆ្នាំសារពើពន្ធ ២០២២-២០២៣ ៖** ឯកសារហិរញ្ញវត្ថុទាំងអស់ដំណើរការតាមប្រព័ន្ធឌីជីថល ទាំងសម្រាប់អង្គការភ្លែនអន្តរជាតិកម្ពុជា និងស្ថាប័នដៃគូ។<br>• **ឆ្នាំសារពើពន្ធ ២០២៣ ៖** អនុវត្តប្រព័ន្ធគ្រប់គ្រងការបើកប្រាក់បៀវត្សរ៍តាមប្រព័ន្ធឌីជីថល។<br>• **ឆ្នាំសារពើពន្ធ ២០២៣-២០២៤ ៖** ស្វែងយល់ពីគំរូស្វ័យសេវាផ្នែករដ្ឋបាល ដូចជាការកក់សំបុត្រយន្តហោះ កន្លែងស្នាក់នៅ ភស្តុភារ ការជាវទ្រព្យទ្រាយតូចៗ។ល។<br>• **ឆ្នាំសារពើពន្ធ ២០២២-២០២៦ ៖** បន្តលើកកម្ពស់ចំណេះដឹងផ្នែកឌីជីថលដើម្បីបង្កើនសមត្ថភាពរបស់បុគ្គលិក។<br>• **ឆ្នាំសារពើពន្ធ ២០២២-២០២៦ ៖** បង្កើនការប្រើប្រាស់ប្រព័ន្ធឌីជីថលគ្រប់គ្រងក្រុមបុគ្គលិក។ |
| | **លទ្ធផល ៣.២៖** ការរៀបចំកម្មវិធី និងកិច្ចសហការស្វែងរកមតិគាំទ្រដោយបច្ចេកវិទ្យាឌីជីថល។ | • **ឆ្នាំសារពើពន្ធ ២០២២៖** ទាញប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល និងភាពជាដៃគូជាមួយសាជីវកម្មឌីជីថល ក្នុងការឆ្លើយតបរបស់អង្គការភ្លែនអន្តរជាតិកម្ពុជាទៅនឹងជំងឺកូវីដ ១៩/គ្រោះអាសន្ន និងក្នុងការកែសម្រួលកម្មវិធី និងកិច្ចសហការស្វែងរកមតិគាំទ្រឱ្យប្រើប្រាស់មធ្យោបាយពីចម្ងាយ។<br>• **ឆ្នាំសារពើពន្ធ ២០២៣-២០២៦ ៖** បង្កើតកម្មវិធី និងកិច្ចសហការស្វែងរកមតិគាំទ្រថ្មីតាមប្រព័ន្ធឌីជីថលដើម្បីផ្តល់ផលប្រយោជន៍កាន់តែច្រើនសម្រាប់ក្មេងស្រី។<br>• អនុវត្តបច្ចេកវិទ្យាឌីជីថលក្នុងការប្រមូល និងវិភាគទិន្នន័យនៅក្នុង MERL។ |

# សូមចូលរួមទាំងអស់គ្នា!

ដើម្បីផ្តល់ផលប្រយោជន៍យូរអង្វែងដល់ជីវិតរបស់
ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង រាប់លាននាក់
នៅកម្ពុជា

ក្នុងនាមជាអង្គការអភិវឌ្ឍន៍ និងមនុស្សធម៌ដែលលើកកម្ពស់សិទ្ធិកុមារ និងសមភាពក្មេងស្រី
អង្គការភ្លែនអន្តរជាតិមិនអត់អោនចំពោះរាល់ករណីនៃការរំលោភបំពាន និងអំពើហិង្សាលើកុមារ ឬ យុវជនឡើយ។

# ២,៥ លាន ហេតុផល

សហការក្នុងភាពជាដៃគូយុទ្ធសាស្ត្រ
ដើម្បីលើកកម្ពស់សិទ្ធិអំណាចរបស់

**ក្មេងស្រី ជាពិសេស ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេង**

## ២,៥លាននាក់

នៅប្រទេសកម្ពុជា ២០២១-២០២៦

PLAN INTERNATIONAL


+855 (0) 23 217 214
www.plan-international.org/cambodia
Plan International Cambodia
Plan International Cambodia
Plan International Cambodia
Plan International Cambodia